**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics


# សារណាបញ្ចប់ការសិក្សា

# ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន យោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២


ស្រាវជ្រាវឡើងដោយ

និស្សិតឈ្មោះ ៖ កញ្ញា **ហ៊ួ ស្រីលីន**

កញ្ញា **សោម ស្រីពេជ្រ**

សាស្ត្រាចារ្យណែនាំ

លោក **ជ្រ សុតារ៉ា**


ថ្នាក់បរិញ្ញាបត្រ៖ នីតិសាស្ត្រ

ជំនាន់ទី៖ **២២**

ឆ្នាំចូលសិក្សា ៖ **២០១៨**

ឆ្នាំសរសេរសារណា ៖ **២០២២**

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **ហ៊្ល ស្រីលីន** និង **សោម ស្រីពេជ្រ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២២ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៨–២០២២ ។

សូមគោរពលំអោនកាយវាចាចិត្តសម្តែងនូវកតញ្ញូតាធម៌ដឹងគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ៖

លោក ឪពុក៖ **ឈៀវ សុវណ្ណា** លោក ឪពុក៖ **សោម សុផាត**

អ្នកម្តាយ៖ **លឹម ចន្ថា** អ្នកម្តាយ៖ **ឯម ឈួន**

ដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ជួយទំនុកបំរុងដល់រូបកូនៗទាំង ស្មារតី និងសម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់នូវដំបូន្មានដ៏ល្អៗរបស់លោកដល់រូបកូនទាំងពីរ ចាប់តាំងពីកុមារភាព រហូតដល់កូនធំពេញវ័យ ថែមទាំងបានទទួលនូវការបណ្តុះបណ្តាលតាំងពីថ្នាក់បឋម សិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកទាំងពីរបានព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ខ្លួនក្នុងការ ជួយទំនុកបំរុងតម្រង់ទិស អោយកូនៗមានអនាគតភ្លឺស្វាងរីកចម្រើនទៅមុខ និងអភិវឌ្ឍខ្លួនអោយក្លាយជាសិស្ស ល្អ កូនល្អ និងពលរដ្ឋល្អនៅក្នុងសង្គមនាថ្ងៃអនាគត ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោក លោកស្រី សាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលពោរពេញដោយសមត្ថភាព ខ្ពង់ខ្ពស់ និងបានជួយតម្រង់ទិសពួកយើងចាប់តាំងពី ឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូត បញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ប្រកបដោយក្រមវិជ្ជាជីវៈ ។

លោកគ្រូសាស្ត្រាចារ្យ **ជ្រ សុនារ៉ា** ដែលលោកបានខិតខំដឹកនាំបង្ហាត់បង្ហាញនូវគំនិត និងវិធីសាស្ត្រ ល្អៗទាក់ទងនឹងប្រធានបទ រួមទាំងបានចំណាយពេលវេលាដ៏មានតម្លៃរបស់លោកក្នុងការជួយផ្តល់ជាគំនិត យោបល់ និងដំបូន្មានល្អៗ និងផ្តល់ឯកសារសម្រាប់ជាប្រយោជន៍ដល់យើងខ្ញុំទាំងពីរនាក់ក្នុងការធ្វើឱ្យសារណា មួយនេះកាន់តែមានភាពល្អប្រសើរឡើងតាំងពីដើមរហូតដល់បញ្ចប់កិច្ចការស្រាវជ្រាវមួយនេះ។ ស្នាដៃដែលកើត ចេញពីការស្រាវជ្រាវមួយនេះ ពិតជាមិនអាចមានអត្ថិភាពឡើយប្រសិនបើគ្មានការជ្រោមជ្រែងពីលោក។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមធ្វើការថ្លែងអំណរអរគុណនឹងដឹងគុណម្តងទៀតដល់អ្នកមាន គុណទាំងពួងដូចដែលបានរៀបរាប់ខាងលើ សូមឱ្យបានជួបតែសេចក្តីសុខ និង ជោគជ័យគ្រប់ភារកិច្ចដោយ ប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈសុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# **អំណរគុណ**

ជាកិច្ចចាប់ផ្តើមដំបូង នាងខ្ញុំឈ្មោះ **ហ៊ូ ស្រីលីន** និង នាងខ្ញុំឈ្មោះ **សោម ស្រីពេជ្រ** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចពិតជាមានសេចក្តីសោមនស្ស រីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សាមួយនេះ។ រូបយើងខ្ញុំទាំងពីរសូមធ្វើការស្វាគមន៍យ៉ាងកក់ក្តៅដល់ប្រិយមិត្តអ្នកអានគ្រប់ទិសទី ជាពិសេសមិត្តនិស្សិតជាទីរាប់អាន និង សាស្ត្រាចារ្យ ជាទីគោរព។ សារណានេះមានចំណងជើងថា « **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន** » ដែលមានគោលបំណងឱ្យអ្នកអានបានយល់ដឹងស៊ីជម្រៅពីសិទ្ធិជាមូលដ្ឋានលើការទទួលខុសត្រូវរបស់អនីតិជន ព្រមទាំងនីតិវិធី និង ទោសព្រហ្មទណ្ឌដែលអនុវត្តលើអនីតិជនដែលកើតមានឡើងក្នុងពេលបច្ចុប្បន្ននេះ។ ប្រធានបទមួយនេះក៏កើតចេញពីចម្ងល់និងការចង់ដឹងឱ្យកាន់តែស៊ីជម្រៅរបស់យើងទាំងពីររូប ទៅលើកិច្ចទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជនក្រោមច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ កិច្ចការស្រាវជ្រាវមួយនេះផ្តោតសំខាន់ទៅលើការអនុវត្តនីតិវិធី ការការពារទៅលើអនីតិជនធ្វើយ៉ាងណាធានាដល់ឧត្តមប្រយោជន៍របស់អនីតិជន។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកសាស្ត្រាចារ្យ **ជ្រ សុនារ៉ា** ជាសាស្ត្រាចារ្យនៃមហាវិទ្យាល័យនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជំរុញទឹកចិត្ត និងបង្ហាត់បង្ហាញ ឆ្លៀតពេលវេលាក្នុងការណែនាំដល់រូបខ្ញុំទាំងពីររហូតអាចបញ្ចប់ការសរសេរសារណានេះ។ នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើនក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗពីបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំសង្ឃឹមថា សារណាមួយនេះអាចជាចំណែកនៃគុណប្រយោជន៍មួយចំនួនដើម្បីជាជំនួយជួយដល់ការសិក្សាស្រាវជ្រាវបន្ថែមរបស់និស្សិតជំនាន់ក្រោយៗ ដែលមានបំណងក្នុងការសិក្សាស្វែងយល់នូវប្រធានបទនេះ និង ទទួលមតិរិះគន់ជានិច្ចពីគ្រប់សំណាក់មជ្ឈដ្ឋាន ទុកជាទុនក្នុងការស្ថាបនានូវសារណានេះឱ្យកាន់តែមានអត្ថន័យ ខ្លឹមសារត្រឹមត្រូវ និង កាន់តែល្អប្រសើរថែមមួយកម្រិតទៀត។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមថ្លែងការគោរពអរគុណយ៉ាងជ្រាលជ្រៅនិងសូមជូនពរដល់លោក លោកស្រីសាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិត ពិសេសមិត្តអ្នកអានឱ្យជួបតែសេចក្តីសុខដុមរមនា និងជោគជ័យគ្រប់ភារកិច្ច។ យើងខ្ញុំសង្ឃឹមថាយុវជន យុវនារីនឹងខិតខំសិក្សារៀនសូត្រ ស្វែងយល់ និង ធ្វើការសិក្សាស្រាវជ្រាវដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ....... ១

## ជំពូកទី១

## បទបញ្ញាតិទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

**ផ្នែកទី១ សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន** ....... ៤

១.១. គោលបំណងនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ....... ៤

១.២. គោលដៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ....... ៤

១.៣. វិសាលភាព ....... ៥

១.៤. និយមន័យ ....... ៥

**ផ្នែកទី២ លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន** ....... ៦

២.១.លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ ....... ៧

២.២. លក្ខខណ្ឌអាយុចាប់ពី១៤(ដប់បួន)ឆ្នាំដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ ....... ៩

**ផ្នែកទី៣ កាលៈទេសៈនៃបទល្មើស និង បុគ្គលិកលក្ខណៈ** ....... ១០

៣.១. កាលៈទេសៈនៃបទល្មើស ....... ១០

៣.២. បុគ្គលិកលក្ខណៈរបស់អនីតិជន ....... ១១

## ជំពូកទី២

## នីតិវិធីនៃការអនុវត្តទៅលើអនីតិជន

**ផ្នែកទី១. ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត** ....... ១២

១.១. សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ....... ១៣

១.២. នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ឆ្នាំ ....... ១៣

១.៣. អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ....... ១៤

១.៣.១. ការចាប់ខ្លួន ....... ១៤

១.៣.២. ការឆែកឆេរ ....... ១៦

១.៣.៣. ការឃាត់ខ្លួន ....... ១៦

១.៣.៤. ការស្តាប់ចម្លើយ ....... ១៧

**ផ្នែកទី២. ដំណាក់កាលអង្គការអយ្យការ** ............ ១៨
២.១. សមត្ថកិច្ចរបស់តំណាងអយ្យការ ............ ១៨
២.១.១. ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ............ ១៨
២.១.២. ការស្តាប់ចម្លើយរបស់អនីតិជន ............ ១៩
២.២. សេចក្តីសម្រេចរបស់តំណាងអយ្យការ ............ ២០
២.២.១.ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម១៤ឆ្នាំ ............ ២០
២.២.២. អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ ............ ២០
**ផ្នែកទី៣. ដំណាក់កាលស៊ើបសួរ** ............ ២១
៣.១. ការបើកការស៊ើបសួរ និងការបង្ហាញខ្លួនរបស់អនីតិជននៅពេលស៊ើបសួរ ............ ២២
៣.១.១. ការប្រាប់អំពីសិទ្ធិរបស់អនីតិជន ............ ២៣
៣.១.២. ការស្តាប់ចម្លើយអនីតិជន ............ ២៣
៣.១.៣. ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន ............ ២៣
៣.២. អំណាចរបស់ចៅក្រមស៊ើបសួរ ............ ២៤
៣.២.១. អំណាចក្នុងការបង្វែរ ............ ២៤
៣.២.២. អំណាចក្នុងការឃុំខ្លួនបណ្តោះអាសន្ន ............ ២៥
៣.២.៣. អំណាចក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ............ ២៥
៣.២.៤. ការបង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំ ............ ២៦
៣.៣. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ............ ២៧
៣.៤. ការប្តឹងទៅសភាស៊ើបសួរ នៃសាលាឧទ្ធរណ៍ ............ ២៨
**ផ្នែកទី៤ ដំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ** ............ ២៨
៤.១. សមត្ថកិច្ចនៃចៅក្រមជំនុំជម្រះ ............ ២៨
៤.២.នីតិវិធីមុនពេលសវនាការ ............ ២៨
៤.៣ ដំណើរការសវនាការ ............ ២៩
៤.៤. ការឲ្យរួចផុតពីបទចោទ ............ ៣០
៤.៥. ការប្រកាសសាលក្រម ............ ៣១
៤.៦. អំណាចរបស់តុលាការក្នុងការបង្វែរ ............ ៣១

## ជំពូកទី៣

## វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

**ផ្នែកទី ១  ការផ្តន្ទាទោស និងការអនុវត្តទោស** ........................................ ៣៣

១.១. ការផ្តន្ទាទោសចំពោះអនីតិជន........................................ ៣៣

១.២. ការអនុវត្តទោសចំពោះអនីតិជន ........................................៣៤

១.៣. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន ........................................៣៥

**ផ្នែកទី២ សមត្ថកិច្ចគ្រប់គ្រងអនីតិជន**........................................៣៥

២.១. មណ្ឌលយុវនីតិសម្បទា ........................................៣៥

២.២. សិទ្ធិជាមូលដ្ឋានរបស់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ........................................៣៦

២.៣. ភ្នាក់ងារសង្គមកិច្ច........................................ ៣៧

**សេចក្តីសន្និដ្ឋាន**........................................៣៨

**អនុសាសន៍**........................................ ៤០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.បុព្វហេតុនៃការសិក្សាស្រាវជ្រាវ

ព្រហ្មទណ្ឌ គឺគោលការណ៍មួយប្រភេទ ដែលចែងមកសម្រាប់ដាក់ទោសដល់រាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយពីបទបញ្ញត្តិច្បាប់ ជាពិសេសនោះគឺក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះហើយ នៅពេលមានបទល្មើសមួយកើតឡើង គឺត្រូវតែមានអ្នកទទួលខុសត្រូវព្រហ្មទណ្ឌ។ ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ ព្រោះថា ការយល់ដឹងខុសត្រូវអំពីអំពើរបស់ខ្លួន ជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ។

យើងបានដឹងរួចហើយថា ប្រទេសមួយចំនួនបានបង្កើតឱ្យមានវិធាននៃការទទួលខុសត្រូវចំពោះអំពើមួយចំនួនមិនថាជាប្រជាពលរដ្ឋរបស់ខ្លួន ឬជនបរទេសឡើយ ឱ្យតែបានប្រព្រឹត្តបទល្មើសណាមួយដែលបានប៉ះពាល់ដល់សង្គម ឬប្រទេសជាតិរបស់គេត្រូវតែទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួននោះ ហើយក៏មានទណ្ឌកម្មជាច្រើនដើម្បីយកមកអនុវត្តចំពោះបុគ្គលទាំងនោះ មានដូចជា ការទទួលខុសត្រូវព្រហ្មទណ្ឌ ការទទួលខុសត្រូវ រដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬរដ្ឋជាអាទិ៍។

ចំណែកឯព្រះរាជាណាចក្រកម្ពុជាយើងវិញ ក៏មិនខុសពីប្រទេសទាំងនោះផងដែរ នៅពេលដែលមានបទល្មើសមួយបានកើតឡើង ត្រូវតែមាននូវបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ ។ គោលការណ៍ទូទៅនៅក្នុងនីតិព្រហ្មទណ្ឌ ពេលដែលមានបទល្មើសមួយបានកើតឡើង ត្រូវតែមាននូវបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ ។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។ រូបវន្តបុគ្គលមានការបែងចែកជាពីរទៀតគឺ នីតិជន និង អនីតិជន ។ នីតិជន សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ។ ចំពោះ អនីតិជន គឺសំដៅទៅលើជនដែលមានអាយុតិចជាង ១៨ ឆ្នាំ នៅពេលជននេះបានប្រព្រឹត្តបទល្មើស ( យោងតាមអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់បញ្ញត្តិនៃមាត្រា ៤០ បានតម្រូវឱ្យរដ្ឋជាភាគីដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កំរិតអាយុអប្បបរមាក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់កុមារ ) មានន័យថា ក្រោមអាយុអប្បបរមានេះ កុមារត្រូវបានសន្មតជាមុនថា ពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ។

ដូច្នោះ ប្រសិនបើយើងក្រឡេកទៅមើលច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ដែលច្បាប់នេះបានកំណត់ឱ្យមានការទទួលខុសត្រូវ ចំពោះទង្វើរបស់ខ្លួនជម្រុញឱ្យមានភាពស្រុះស្រួលរវាងអនីតិជន និងជនរងគ្រោះ ការពារជនរងគ្រោះ និងសហគមន៍ព្រមទាំងជួយដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ហេតុនេះបានជាក្រមព្រហ្មទណ្ឌកម្ពុជាកំរិតអំពីការទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងច្បាស់លាស់ ដែលក្នុងនោះ មាត្រា៣៨ បានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ។ ដោយសង្កេតឃើញថា អនីតិជនជាជនដែលមានសមត្ថភាព យល់ដឹងខាងអំពើនៅមានកម្រិតនៅឡើយ ដូច្នេះ ទើបមាននូវសំណួរចោទសួរឡើងថា **ចុះប្រសិនបើអនីតិជនអាយុក្រោម ១៨ ឆ្នាំ ប្រព្រឹត្តបទល្មើស តើត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែរឬទេ? តើមានវិធានការបែបណាខ្លះ ចំពោះអនីតិជនដែលបាន ប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ**? ជាមួយគ្នានេះដែរ តើគួរមាននូវការអនុវត្តនីតិវិធីពិសេសមួយចំពោះពួកគាត់ ដែរឬទេ? ចុះចំពោះការអនុវត្តទោសវិញ តើនឹងប្រព្រឹត្តទៅមានលក្ខណៈយ៉ាងណាដែរ? ហេតុនេះហើយបានជានៅក្នុងការសិក្សាស្រាវជ្រាវត្រូវតែជ្រើសរើសយកប្រធាននេះមកបកស្រាយដោយសារតែមាននូវចំណោទបញ្ហាគតិយុត្តិទាំងអស់នេះហើយទើបពួកយើង បានធ្វើការសម្រេចចិត្តយ៉ាងមុតមាំថាស្រាវជ្រាវនូវប្រធានបទស្តីពី « **ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនយោងតាមច្បាប់ស្តីពីយុត្តធម៌អនីតិជន** » នេះឡើងមកសរសេរ គឺក្នុងន័យ ដើម្បីដោះស្រាយនូវរាល់ចម្ងល់ដែលបានចោទសួរខាងលើនេះ ។ សំដៅដល់ការទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ អនីតិជនគឺត្រូវទទួលខុសត្រូវចំពោះ បទល្មើសដែលខ្លួនបានប្រព្រឹត្តឡើង។ ពាក្យថា ទណ្ឌកម្មព្រហ្មទណ្ឌក្នុងន័យនេះ គឺសំដៅដល់ការប្រកាសផ្តន្ទាទោសដែលធ្វើឡើងដោយស្ថាប័នតុលាការផ្ទាល់តែម្តង មានន័យថា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ជាគោលការណ៍មួយដែលបានធ្វើការកំណត់ពាក់ព័ន្ធអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់អនីតិជននេះឯង ។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះដែរ គឺធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់អំពីភាពមិនច្បាស់លាស់និង ចម្ងល់មួយចំនួន ក៏ដូចជាចង់ស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែលបានលើកឡើងពីខាងលើស្រាប់។ លើសពីនេះទៅទៀត គឺដើម្បីពង្រឹង និងពង្រីកនូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទង និងវិស័យព្រហ្មទណ្ឌនេះ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាខាងលើនេះ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវនិងស្វែងរកឯកសារថែមទាំងបានជ្រើសរើសឯកសារជាមូលដ្ឋានមួយចំនួនដើម្បីសរសេរសារណានេះឡើង។ ក្នុងនោះរួមមានដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៩ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងរួមទាំងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀត ដូចដែលបានលើកឡើងនៅក្នុងឯកសារពិគ្រោះស្រាប់ ។ នៅក្នុង

ការសិក្សាស្រាវជ្រាវនេះដែរ យើងខ្ញុំសូមផ្តោតតែទៅលើករណីដែលអនីតិជនបានប្រព្រឹត្តនូវបទល្មើសព្រហ្មទណ្ឌ ហើយត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន តែប៉ុណ្ណោះ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សមិទ្ធផលដែលបានទទួលពីការសិក្សាស្រាវជ្រាវនេះ នឹងក្លាយទៅជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់ប្អូនៗនិស្សិតជំនាន់ក្រោយៗទៀតដើម្បីអាចយកទៅធ្វើការសិក្សាស្វែងយល់ក៏ដូចជាអនុញ្ញាតឱ្យប្អូនៗអាចយល់ដឹងកាន់តែច្បាស់អំពីផ្នែកមួយនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជននេះផងដែរ ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះ ដើម្បីឱ្យកាន់តែមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមានប្រសិទ្ធភាពខ្ពស់។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និងដកស្រង់ចេញពីប្រភពល្អៗដូចជាការបកស្រាយរបស់និស្សិត អ្នកមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ មតិយោបល់ពីអ្នកជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជាបន្តទៅទៀត ដើម្បីឆ្លើយតបនឹងប្រធានបទខាងលើនេះ សូមធ្វើការបែងចែកជា ៣ជំពូកធំៗគឺរួមមាន៖

**ជំពូកទី ១ បទបញ្ញត្តិ ទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន**

**ជំពូកទី ២ នីតិវិធីនៃការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី ៣ ការអនុវត្តទោសចំពោះអនីតិជន**

# ជំពូកទី១

# បទបញ្ញត្តិទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

### ១.១. គោលបំណងនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន គឺជានាការពារសិទ្ធិនិងឧត្តមប្រយោជន៍របស់អនីតិជនដែល ប្រព្រឹត្ត បទល្មើស គាំទ្រដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ធានាការពារផលប្រយោជន៍សង្គមនិងសហគមន៍[1]។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានគោលបំណងឱ្យមានការ ទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនជំរុញឱ្យមានភាពស្រុះស្រួលរវាងអនីតិជននឹងជនរងគ្រោះ ការការពារជនរង គ្រោះ និងសហគមន៍ ព្រមទាំងជួយគាំទ្រដល់ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ។ ជាពិសេសការលើកស្ទួយផ្នែកសិទ្ធិមនុស្សរបស់កុមារ ទំនាស់នឹងច្បាប់ ហើយនិងការពារសិទ្ធិ របស់អនីតិជន និងជនរងគ្រោះព្រមទាំងមានការធានាការពារសិទ្ធិ ឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្ត បទល្មើស ។

### ១.២. គោលដៅនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន

ច្បាប់ ជាឧបករណ៍មួយយ៉ាងសំខាន់សម្រាប់គ្រប់គ្រងមនុស្សក្នុងសង្គមមួយ ដែលមានប្រជាពលរដ្ឋ ច្រើនលាននាក់រស់នៅ ហើយបុគ្គលម្នាក់ៗមានចិត្ត គំនិតខុសគ្នាទៅតាមទង្វើ ការប្រព្រឹត្តិរបស់មនុស្សម្នាក់ៗ នោះ។ ដោយសារតែមនុស្សមានគំនិត បញ្ញាស្មារតីនៃការយល់ដឹងផ្សេងៗគ្នានេះហើយ ដែលជាហេតុនាំឱ្យរដ្ឋ ជាតួអង្គដ៏សំខាន់ ក្នុងការបង្កើតនូវក្បួនច្បាប់វិន័យដើម្បីសំដៅនូវវិធីសាស្ត្រដែលអាច គ្រប់គ្រងនិង ដោះស្រាយ រាល់បញ្ហាជម្លោះជូនប្រជាពលរដ្ឋរបស់ខ្លួន។

ដូច្នេះហើយទើបមាន ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធី ទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្តិភាពនៃបទល្មើស ព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន[2]។ ដោយយោងតាមខ្លឹមសារនៃច្បាប់នេះ គឺផ្តោតសំខាន់ទៅលើ យន្តការទាំងឡាយណាដែលផ្តល់ឧត្តមប្រយោជន៍ជូនទៅដល់អនីតិជន ក៏ដូចជាការប្រើប្រាស់នូវនីតិវិធីដោះ ស្រាយមួយដែលមានការគោរពទៅដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរដែលជាកត្តាមួយនាំឲ្យមានភាពមិនស្មើ ភាពគ្នាចំពោះមុខច្បាប់ រវាងការប្រព្រឹត្តនូវបទល្មើសដូចគ្នាដែលបង្កឡើងដោយនីតិជន និងអនីតិជន ។

---

[1] មាត្រា១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[2] មាត្រា២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

## ១.៣. វិសាលភាព

ច្បាប់នេះមានវិសាលភាពអនុវត្តលើករណីអនីតិជនដែលប្រព្រឹត្តបទល្មើស[3]។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏មានវិសាលភាពគ្រប់គ្រងទៅលើប្រព័ន្ធយុត្តាធិការ និងការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌របស់អនីតិជន។ ច្បាប់នេះអនុវត្តបានចំពោះតែអនីតិជនណាមួយដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើស និងនៅពេលប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ចំពោះអនីតិជននោះត្រូវមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ និងជនដែលមានអាយុឈានចូល១៨ឆ្នាំ នៅមុនពេល អនុវត្តនីតិវិធីនានាមកលើខ្លួន ។ មិនត្រឹមតែប៉ុណ្ណោះ ការអនុវត្តចំពោះអនីតិជនដែលជាប់សង្ស័យ ឬជនត្រូវចោទ ឬជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើសផ្ទុយនឹងច្បាប់ ឬជនដែលត្រូវបានតុលាការកាត់ទោសរួចហើយ ។ អនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ ជាច្បាប់មួយដែលចែងបន្ថែម និង គ្របដណ្តប់ពីលើច្បាប់ដែលនៅជាធរមានស្រាប់ដូចជាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ។ ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវមានវិសាលភាពអនុវត្តដោយគតលម្អៀងចំពោះអនីតិជន ដែលល្មើសដោយមិនប្រកាន់អ្វីទាំងអស់ដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា ស្ថានភាពកំណើតឬស្ថានភាពដទៃទៀត។

## ១.៤. និយមន័យ

- **យុត្តិធម៌អនីតិជន៖** សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស[4]។
- **អាជ្ញាធរមានសមត្ថកិច្ច៖** សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។
- **អនីតិជន៖** សំដៅដល់ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។
- **អនីតិជនត្រូវការកិច្ចការពារ និងថែទាំ៖** សំដៅដល់អនីតិជន ដែលត្រូវការកិច្ចការពារនិងថែទាំ ដោយមូលហេតុអនីតិជននោះគ្មានអ្នកតំណាង ដែលច្បាប់បានកំណត់ ឬគ្មានការថែទាំ និងគ្រប់គ្រងត្រឹមត្រូវពីសំណាក់អ្នកតំណាងច្បាប់បានកំណត់ហើយកំពុងប្រឈមនឹងសភាពគ្រោះថ្នាក់ ឬរងការរំលោភ

[3] មាត្រា៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[4] មាត្រា៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

បំពាន ឬបង្ហាញការគំរាមកំហែងដល់សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬគំរាមកំហែងដល់សុវត្ថិភាពផ្ទាល់ខ្លួន ។

- **អ្នកតំណាងដែលច្បាប់បានកំណត់៖** សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។
- **អ្នកទំនុកបម្រុង៖** សំដៅដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលត្រូវបានជ្រើសរើសដោយអនីតិជន ឬដោយអាជ្ញាធរមានសមត្ថកិច្ច និងមានការយល់ព្រមពីអនីតិជនឲ្យទទួលខុសត្រូវក្នុងការទំនុកបម្រុងខ្លួនក្នុងអំឡុងពេលអនុវត្តនីតិវិធីដែលមានចែងក្នុងច្បាប់នេះ ។
- **ភ្នាក់ងារសង្គមកិច្ច៖** សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។
- **មណ្ឌលយុវនីតិសម្បទា៖** សំដៅដល់មណ្ឌលដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ផ្តល់សេវាការពារ ថែទាំ អប់រំ ស្តារនីតិសម្បទា និងសមាហរណកម្មដល់អនីតិជន។

## ផ្នែកទី២ ៖ លក្ខខណ្ឌដែលនាំឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

ជាគោលការណ៍ទូទៅ នៅក្នុងក្រមព្រហ្មទណ្ឌនៅពេលមានបទល្មើសមួយកើតឡើង ទោះអំពើនោះប្រព្រឹត្តឡើងដោយចេតនាក្តី ឬ អចេតនាក្តី ដែលជាហេតុបណ្តាលឲ្យមានព្យសនកម្មដល់បុគ្គលដទៃ គឺជាលក្ខខណ្ឌចម្បងនៃការទទួលខុសត្រូវព្រហ្មទណ្ឌ។ រីឯនីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់ចាប់ពីអាយុ១៨ (ដប់ប្រាំបី)ឆ្នាំ ឡើងទៅ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ ក្រោម១៨ (ដប់ប្រាំបី)ឆ្នាំ បានផងដែរប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ [5] ។ ម្យ៉ាងទៀតអាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនត្រូវកំណត់យកអាយុនៅពេលដែលអនីតិជននោះប្រព្រឹត្តបទល្មើស ភស្តុតាងនៃអាយុរបស់អនីតិជន ត្រូវបានបញ្ជាក់ដោយសំបុត្រកំណើត ឬឯកសារផ្សេងទៀតដែលអាចបញ្ជាក់បានអំពីកំណើត។ ក្នុងករណីពុំមានឯកសារ ឬមានការសង្ស័យ ឬមិនមានភាពច្បាស់លាស់ទាក់ទងនឹងយថាភូតនៃឯកសារនោះ ភស្តុតាងនៃអាយុរបស់អនីតិជនអាចផ្តល់តាមគ្រប់មធ្យោបាយផ្សេងទៀតដែលអាជ្ញាធរតុលាការអាចជឿទុកចិត្តបាន។ អាជ្ញាធរមាន

[5] មាត្រា៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

សមត្ថកិច្ចត្រូវស្វះស្វែងរកភស្តុតាង ដើម្បីកំណត់អាយុរបស់អនីតិជនឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជននោះ[6] ។ ការលំបាកក្នុងការកំណត់អាយុពិតរបស់អនីតិជននៅត្រង់ថា មិនទាន់មានវិធីសាស្ត្របញ្ជាក់ពីអាយុតាមលក្ខណៈវិទ្យាសាស្ត្រ ឬ វេជ្ជសាស្ត្រឲ្យបានត្រឹមត្រូវនៅឡើយ។

សម្រាប់គោលបំណងកំណត់អាយុនៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌរបស់បុគ្គល ដែលមានអាយុរបស់ខ្លួនដែលត្រូវជាជនជាប់សង្ស័យនោះគឺ ជាអាយុនៅពេលដែលជននោះប្រព្រឹត្តបទល្មើសដែលត្រូវបានចោទដោយយើងយោងទៅតាមភស្តុតាងនៃការកំណត់អាយុរបស់បុគ្គលនោះ ដែលត្រូវផ្តោតទៅលើសំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើត។ ផ្ទុយទៅវិញប្រសិនបើក្នុងករណីពុំមានឯកសារដែលបានបញ្ជាក់ខាងលើនោះទេ ឬ មានបញ្ហាទាក់ទង នឹងលិខិតយថាភូតឯកសារនោះដែល ភស្តុតាងនៃអាយុរបស់បុគ្គលរូបនោះយើងត្រូវធ្វើយ៉ាងណាដោយប្រើប្រាស់គ្រប់ ការស្រាវជ្រាវដោយតាមរយៈមធ្យោបាយ ដែលអាចទុកចិត្តបានផ្សេងៗទៀតដូចជា វេជ្ជកោសល្យវិច្ច័យ លើកំណត់ត្រាសុខភាព កំណត់ត្រាផ្នែកពេទ្យកំណត់ត្រាផ្នែកទន្តសាស្ត្រ កំណត់ត្រារបស់សាលារៀន ការស្បថក្នុងការផ្តល់សក្ខីកម្មដោយជនជាសាច់ញាតិជាពិសេស គឺពីសំណាក់មន្ត្រីឃុំ-សង្កាត់ សមាជិកសហគមន៍ ជនផ្សេងទៀតដែលស្គាល់អនីតិជន ។ ប៉ុន្តែដោយយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានកំណត់ថាក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់ជនសង្ស័យនោះនាំឲ្យមានហេតុផលដែលជឿបានថាជនជាប់សង្ស័យអនីតិជនមានអាយុតិចជាងអាយុជាក់លាក់ណាមួយដែលមានសិទ្ធិទទួលនូវការប្រព្រឹត្តពិសេសដែលជាការផ្តល់ឱកាសឲ្យអនីតិជន ត្រូវបានអនុវត្តតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ ។

ជាមួយគ្នានេះដែរ ដើម្បីឆ្លើយតបទៅនឹងលក្ខខណ្ឌអាយុខាងលើ យើងខ្ញុំធ្វើការបែងចែកអនីតិជនជាពីរប្រភេទគឺៈ លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ និង លក្ខខណ្ឌអាយុចាប់ពី១៤(ដប់បួន)ឆ្នាំដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ។

### ២.១. លក្ខខណ្ឌអាយុក្រោម១៤(ដប់បួន)ឆ្នាំ

អនីតិជនដែលមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នៅពេលដែលប្រព្រឹត្តបទល្មើសគឺច្បាប់បានកំណត់ថាមិនឲ្យទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយហេតុថា ទាញចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារត្រង់មាត្រា ៤០ ចំណុចទី៣កថាខណ្ឌ"ក" បានតម្រូវឲ្យរដ្ឋភាគី ដែលក្នុងនោះក៏មានព្រះរាជាណាចក្រកម្ពុជាផងដែរ ត្រូវធ្វើការកំណត់កំរិតអាយុអប្បបរមា នៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់កុមារដែលមានអាយុក្រោមអប្បបរមានេះ

[6] មាត្រា៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

កុមារត្រូវបានសន្មតជាមុនថាពុំមានសមត្ថភាពនឹងប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌឡើយ[7]។ រីឯមាត្រា១៤កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ បានចែងថាអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រគល់ជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់[8]។ ចំណែកឯមាត្រា ២៧នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន កថាខណ្ឌទី១ ក៏បានចែងផងដែរថា ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ (ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការនិង ត្រូវប្រគល់អនីតិជនទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់វិញភ្លាម។តាមខ្លឹមសារខាងលើនេះ អាចនាំឲ្យគេសន្មតបានថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ជាកម្រិតអាយុអប្បបរ មានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬ អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ ពុំទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។

ឧទាហរណ៍៖ ក្មេងប្រុសអាយុ ១០ (ដប់) ឆ្នាំ ម្នាក់បានយកដំបងទៅវាយក្បាលក្មេងប្រុសម្នាក់ទៀតដែលឈរក្បែរនោះ បណ្តាលឲ្យបែកក្បាលរងរបួសជាដំណំ។ ក្នុងករណីនេះ ក្មេងដែលបានប្រព្រឹត្តបទល្មើសនោះ មិនអាចត្រូវទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ អាស្រ័យដោយហេតុថាក្មេងនោះនៅមិនទាន់មានការយល់ដឹងខុសត្រូវពីអំពើរបស់ខ្លួននៅឡើយ។

គួរកត់សម្គាល់ដែរថា អនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ សច្ចធារណ៍មិនអាចប្រកែកបាននៃការមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ដែលរារាំងចំពោះការចូលខ្លួនមកកាន់តុលាការ និងការប្រកាសសេចក្តីសម្រេចនោះទេ (ការស្តីបន្ទោស ឬ វិធានការអប់រំ)។

ដូច្នេះ តុលាការក៏នៅតែអាចធ្វើការកោះហៅអនីតិជននោះឲ្យចូលខ្លួនមកកាន់តុលាការបានផងដែរ ក្នុងគោលបំណងដើម្បីប្រកាសសេចក្តីសម្រេចដាក់ឲ្យអនុវត្តវិធានការណាមួយ ដែលតុលាការបានធ្វើការសម្រេច លើអនីតិជននោះ។ វិធានការទាំងនោះរួមមាន៖ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ ឬ ក៏ប្រគល់អនីតិជននោះទៅឲ្យសាច់ញាតិ សេវាសាធារណៈ អង្គការឯកជនដែលមាននីតិសម្បទា មន្ទីរពេទ្យ ឬ ស្ថាប័នឯកទេស និង អាចដាក់អនីតិជននោះ ឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការបានផងដែរ។

[7] មាត្រា១០ នៃអនុសញ្ញាស្តីពីកុមារ

[8] មាត្រា១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

## ២.២. លក្ខខណ្ឌអាយុចាប់ពី១៤(ដប់បួន)ឆ្នាំដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ

ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ វិញ នៅពេលដែលអនីតិជនប្រភេទនេះបានប្រព្រឹត្តបទល្មើស គឺត្រូវទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្តនោះ។ ហេតុដែលច្បាប់តម្រូវឲ្យមានការទទួលខុសត្រូវ ព្រោះយល់ឃើញថា អនីតិជនប្រភេទនេះ មានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌហើយ[៩]។ សមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាលទ្ធភាពរបស់មនុស្សនៅពេលដែលប្រព្រឹត្តអំពើបង្កគ្រោះថ្នាក់ដល់សង្គម ហើយជននោះអាចយល់ដឹងអំពីចរិតគ្រោះថ្នាក់នៃអំពើរបស់ខ្លួន និងអាចយល់ពីបញ្ជានូវរាល់អំពើទាំងនោះបាន។ការយល់ឃើញយ៉ាងដូច្នេះ នីតិករបានពិចារណាដោយផ្អែកទៅលើ ការរីកចម្រើនអំពីរូបរាងកាយ ប្រាជ្ញា ស្មារតី និងការសន្សំនូវបទពិសោធន៍នៃជីវិតក្នុងជីវភាពរស់នៅរបស់អនីតិជននោះឯង។ កត្តាទាំងអស់នេះហើយ ដែលជាហេតុនាំឲ្យច្បាប់សន្មតបានថា អនីតិជនប្រភេទនេះអាចពិចារណាយល់ដឹងបានគ្រប់គ្រាន់នូវរាល់ការទាមទារ និងរបបកំណត់របស់សង្គម ព្រមទាំងអាចបញ្ជាបាននូវរាល់អំពើរបស់ខ្លួនថែមទៀតផង។ ថ្វីត្បិតតែច្បាប់បានតម្រូវឲ្យ អនីតិជនប្រភេទនេះមានការទទួលខុសត្រូវទៅលើអំពើដែលខ្លួនបានប្រព្រឹត្តក៏ពិតមែន ប៉ុន្តែការទទួលខុសត្រូវនេះមិនមានលក្ខណៈពេញលេញដូចនីតិជនឡើយ ពោលគឺស្ថានភាពដែលជននេះត្រូវទទួលរងគឺ មានកម្រិតស្រាលជាងនីតិជន។ ហើយដើម្បីអាចសម្រេចផ្តន្ទាទោសលើអនីតិជនបាន តុលាការត្រូវពិចារណាថ្លឹងថ្លែងជាមុនសិនពាក់ព័ន្ធទៅនឹងកាលៈទេសៈនៃបទល្មើសដែលអនីតិជននេះបានប្រព្រឹត្ត និងរួមទាំងបុគ្គលិកលក្ខណៈរបស់អនីតិជនប្រភេទនេះផងដែរ។ ចំពោះទោសដែលត្រូវទទួលរងវិញគឺ អាចមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ឬអាចហៅបានម៉្យាងទៀតថា មូលទោស។សូមបញ្ជាក់ថា បើទោះបីជាអនីតិជនអាចទទួលរងនូវទោសបែបនេះក៏ដោយ ក៏កម្រិតនៃទោសដែលទទួលរងគឺត្រូវបន្ថយមកត្រឹមពាក់កណ្តាល បើប្រៀបធៀបទៅនឹងទោសដែលមានចែងចំពោះនីតិជន។ ជារួម គេអាចយល់បានថា ការបន្ថយទោសចំពោះអនីតិជនអាច បណ្តាលមកពីមូលហេតុអនីតិភាពនៃទណ្ឌិតនេះឯង។

ឧទាហរណ៍៖ ក្មេងស្រី **ក** មានអាយុ ១៥ (ដប់ប្រាំ) ឆ្នាំ បានឈ្លោះប្រកែកជាមួយក្មេងប្រុស **ខ**។ នៅពេលឈ្លោះប្រកែកនោះក្មេងស្រី **ក** បានជ្រុលដៃចាក់ក្មេងប្រុស **ខ** មួយកាំបិតចំកញ្ចឹងកបណ្តាលឲ្យស្លាប់។ អំពើដែលក្មេងស្រី **ក** បានប្រព្រឹត្តមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។ ដូច្នេះ ចំពោះទោសដែលត្រូវអនុវត្តចំពោះក្មេងស្រីនោះគឺត្រូវបន្ថយមកត្រឹមពាក់កណ្តាលបើធៀបទៅនឹងទោសដែលត្រូវអនុវត្តចំពោះនីតិជន។

---

[៩] សៀវភៅសារណា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនរៀបរៀងដោយណែម យ៉ុងអ៊ី និង ជា ស្រីល័ក្ខ

អនីតិជនមិនទាន់ចាត់ទុកថាមានភាពចាស់ទុំ ឬមានការទទួលខុសត្រូវគ្រប់គ្រាន់និងវិនិច្ឆ័យលើអំពើរបស់ខ្លួនដូចជាមនុស្សពេញវ័យនោះទេ។

## ផ្នែកទី៣ ៖ កាលៈទេសៈនៃបទល្មើស និង បុគ្គលិកលក្ខណៈ

យោងតាមគោលការណ៍នៃការកំណត់ទណ្ឌកម្ម ឬ គោលការណ៍ក្នុងការកំណត់ការផ្តន្ទាទោស ចៅក្រមដើម្បីអាចផ្តន្ទាទោសជនល្មើសម្នាក់បាន ត្រូវពិចារណាអំពីបាតុភូតសង្គមដែលជាបទល្មើសបានកើតឡើងឲ្យបានគ្រប់ជ្រុងជ្រោយជាមុនសិន ទើបធ្វើការសម្រេចផ្តន្ទាទោសទៅលើចារីនោះបាន។ មានន័យថា ដើម្បីអាចចេញនូវ សេចក្តីសម្រេចប្រកបដោយសុក្រិត្យភាព និងសុភវិនិច្ឆ័យ ចៅក្រមត្រូវពិចារណាទៅលើបីចំណុចសំខាន់ៗគឺ

- ត្រូវពិចារណាពាក់ព័ន្ធនឹងបញ្ហាដែលមានចែងនៅក្នុងច្បាប់ ពោលគឺសំដៅទៅដល់គោលការណ៍នីត្យានុកូលនៃទោស។
- ត្រូវពិចារណាទៅលើស្ថានភាពនៃការប្រព្រឹត្តបទល្មើសថា តើបទល្មើសនោះបានប្រព្រឹត្តនៅក្នុងកាលៈទេសៈណា? ពេលវេលាណា? ទីកន្លែងណា?
- ត្រូវពិនិត្យទៅលើបុគ្គលិកលក្ខណៈរបស់ជនល្មើសនោះផងដែរ។ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដោយផ្តោតលើកាលៈទេសៈនៃបទល្មើស(១) ឬបុគ្គលិកលក្ខណៈរបស់អនីតិជន(២)។

### ៣.១. កាលៈទេសៈនៃបទល្មើស

នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាមាត្រា ៣៨ បានកំណត់ថា ការទទួលខុសត្រូវព្រហ្មទណ្ឌបានលុះត្រាតែមានអាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ ដោយហេតុថាអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គឺជាអនីតិជនដូចនេះការយល់ដឹងរបស់ពួកគេនៅមានភាពខ្វះខាតនៅឡើយ តែប្រសិនបើ អនីតិជនបានប្រព្រឹត្តបទល្មើសអ្វីមួយនោះ វិធានការអនុវត្តចំពោះអនីតិជនគឺមានតែ វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ។ ប៉ុន្តែចំណុចនេះអាចមានការពិបាក ដោយហេតុថា ក្នុងករណីដែលមានអនីតិជនអាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ ប្រព្រឹត្តបទល្មើសដែលមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ។ ប៉ុន្តែនៅក្នុងមាត្រា ៣៩ កថាខណ្ឌទី ២ បានបញ្ញត្តិបន្ថែមថា តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ឡើងទៅបាន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[10]។ មានន័យថា អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ អាចនឹងត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

[10] មាត្រា៣៩ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

ចំពោះអំពើរបស់ខ្លួន ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ។ នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា មិនបានកំណត់ឲ្យបានច្បាស់លាស់នូវឡើយអំពីពាក្យថាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន។ ដូចនេះនៅពេលជួបប្រទះករណីណាមួយ ច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការដែលគេហៅម៉្យាងទៀតថា ឆន្ទានុសិទ្ធិក្នុងការគិតពិចារណាថា តើអនីតិជននោះត្រូវទទួលខុសត្រូវ ឬក៏អត់ចំពោះទង្វើល្មើសច្បាប់ព្រហ្មទណ្ឌរបស់ខ្លួន។

### ៣.២. បុគ្គលិកលក្ខណៈរបស់អនីតិជន

ជាទូទៅរាល់អនីតិជនអាយុ ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសទាំងអស់តុលាការអាចសម្រេចដាក់ត្រឹមតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះដែលមានដូចជា[11]៖

១.ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។

២.ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣.ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។

៤.ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។

៥.ការដាក់អនីតិជនឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ ត្រង់ចំណុចនេះ មានន័យថា តុលាការត្រូវចាត់តាំងបុគ្គលណាមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន បុគ្គលនេះត្រូវផ្ញើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀតទាត់ដល់ព្រះរាជអាជ្ញា។ ការកំណត់បុគ្គលិកលក្ខណៈរបស់ជនល្មើស យើងអាចកំណត់បានតាមរយៈរបបវេជ្ជសាស្ត្រ និងរបបតាមបែបធម្មជាតិ។ ក៏ប៉ុន្តែ ចំពោះអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែលមានស្ថានទម្ងន់ធ្ងន់ធ្ងរ តុលាការអាចសម្រេចផ្តន្ទាទោសអនីតិជនដោយបន្ថយពាក់កណ្តាលនៃទោសដែលអនុវត្តចំពោះនីតិជន។

[11] មាត្រា៤០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

# ជំពូកទី២
# នីតិវិធីនៃការអនុវត្តនៅលើអនីតិជន

នីតិវិធីអនុវត្តចំពោះអនីតិជន មានលក្ខណៈដូចគ្នាទៅនឹងនីតិវិធីដែលអនុវត្តចំពោះនីតិជនដែរ ប៉ុន្តែដោយសារតែសមត្ថភាពនៃការយល់ដឹងរបស់អនីតិជននៅមានកម្រិត ដូច្នេះទើបតម្រូវឲ្យមានការអនុវត្តនូវនីតិវិធីពិសេសមួយចំនួនចំពោះអនីតិជន។ ការអនុវត្តនីតិវិធីនេះត្រូវមានចំណាត់ការទៅតាមដំណាក់កាលនីមួយៗផងដែរ ក្នុងនោះមាន ដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបសួរ ដំណាក់កាលអង្គការអយ្យការ ដំណាក់កាលស៊ើបសួរ និងដំណាក់កាលចៅក្រមជំនុំជម្រះនាពេលសវនាការជាដើម។

## ផ្នែកទី១ ៖ ដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

រឿងក្តីព្រហ្មទណ្ឌ ត្រូវធ្វើឡើងដំបូងដោយមានការស៊ើបអង្កេតពីមន្ត្រីនគរបាលយុត្តិធម៌ ដើម្បីស្វែងរកនូវអង្គហេតុមួយចំនួនក្នុងការចាត់ទុកជាបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ មានភារកិច្ចក្នុងការត្រួតពិនិត្យទៅលើបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ពាក់ព័ន្ធទៅនឹងជនសង្ស័យដែលជាអនីតិជន។ នគរបាលយុត្តិធម៌មានតួនាទីក្នុងការកំណត់នូវអត្តសញ្ញាណ ប្រមូលភស្តុតាង ដើម្បីធ្វើការឃាត់ខ្លួន ឬចាប់ខ្លួនអនីតិជនក្នុងករណីចាំបាច់ ហើយបញ្ជូន ឬប្រគល់របាយការណ៍ និងកំណត់ហេតុលំអិតនៃការចាប់ខ្លួន ឬឃាត់ខ្លួនទៅដល់អង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន ពីព្រោះការស៊ើបអង្កេតពាក់ព័ន្ធទៅនឹងអនីតិជនគឺត្រូវធ្វើឡើងដោយមន្ត្រីជំនាញ ឬមានការជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានការបណ្តុះបណ្តាលស្តីពីយុត្តិធម៌អនីតិជន។

បើសិនក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការអប់រំណែនាំព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ហើយប្រគល់អនីតិជននោះឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ក្នុងករណីដែលអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើសដែលជាបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការសម្របសម្រួលរវាងភាគីពាក់ព័ន្ធ ដើម្បីបញ្ចប់វិវាទ[12]។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ក៏ត្រូវធ្វើរបាយការណ៍ ព្រមទាំងបញ្ជូនសំណុំរឿងនោះទៅកាន់ព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់។ ប្រសិនបើអនីតិជននោះត្រូវការកិច្ចការពារថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកផ្នែកវិស័យសង្គមកិច្ច រាជធានី ខេត្ត ក្រុង ខណ្ឌ ដើម្បីចាត់ការវិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន [13]។

[12] មាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[13] មាត្រា១៣ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

មន្ទីរ ឬការិយាល័យទទួលបន្ទុក វិស័យសង្គមកិច្ចរាជធានី ខេត្តក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ជូនទៅព្រះរាជអាជ្ញា។

### ១.១. សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្រោមការដឹកនាំ ក៏ដូចជាការសម្របសម្រួលសកម្មភាពការងារដោយព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌មានភារៈកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ ដែលប្រព្រឹត្តទៅដោយអនីតិជន និងធ្វើការប្រមូលភស្តុតាង ក៏ដូចជាកំណត់អត្តសញ្ញាណដើម្បីធ្វើការឃាត់ខ្លួន ឬចាប់ខ្លួនអនីតិជនដែលបានប្រព្រឹត្តបទល្មើសក្នុងករណីចាំបាច់។ ការចាប់ខ្លួន និងការស៊ើបអង្កេតលើករណីអនីតិជននេះ ត្រូវធ្វើឡើងដោយមន្ត្រីជំនាញ ឬជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលបានទទួលការបណ្តុះបណ្តាលស្តីពីយុត្តិធម៌ និងអនីតិជនប្រសិនបើអាចធ្វើបាន។ ដូចនេះក្នុងករណីណាមួយក៏ដោយនគរបាលយុត្តិធម៌ដែលបានចាប់ខ្លួនអនីតិជន ឬនគរបាលយុត្តិធម៌ដែលបានឃាត់ខ្លួនអនីតិជនត្រូវប្រគល់របាយការណ៍ និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកផ្នែកការងារអនីតិជន[14]។

### ១.២. នីតិវិធីទាក់ទងនឹងអនីតិជនអាយុក្រោម ១៤ឆ្នាំ

អនីតិជនមានអាយុក្រោម១៤ (ដប់បួន) ឆ្នាំ ដែលជាប់សង្ស័យថាបានប្រព្រឹត្តបទល្មើស ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីមន្ត្រីនគរបាលយុត្តិធម៌ជូនទៅព្រះរាជអាជ្ញា ។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បី

[14] មាត្រា១២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ គ្រប់អំពើដែលជាបទល្មើសទាំងអស់ដែលប្រព្រឹត្តដោយអនីតិជនអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ នគរបាលយុត្តិធម៌ត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា[15]។ លើសពីនេះទៅទៀត ការចាប់ខ្លួនទាំងអស់ត្រូវតែធ្វើការរាយការណ៍ទៅដល់ព្រះរាជអាជ្ញាភ្លាម មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជៀសវាងការធ្វើអោយអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន។

### ១.៣. អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌

ក្នុងករណីណាក៏ដោយប្រសិនបើមានបទល្មើសណាមួយ ដែលប្រព្រឹត្តឡើងដោយអនីតិជន គឺមន្ត្រីនគរបាលយុត្តិធម៌ត្រូវមានតួនាទីក្នុងការឃាត់ ឬចាប់ខ្លួន អនីតិជននោះ ដើម្បីយកមកធ្វើការបំពេញកិច្ចមួយចំនួននៅអង្គភាពនគរបាលយុត្តិធម៌។ មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបន្ទុកលើអនីតិជន មានអំណាចនៅក្នុងការបំពេញកិច្ចរបស់ខ្លួន ដោយផ្អែកទៅលើក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជន។ កិច្ចទាំងនោះអាចជា ការចាប់ខ្លួន ការឆែកឆេរ ការឃាត់ខ្លួន ការជូនដំណឹង ការស្តាប់ចម្លើយ និង ការបញ្ជាប់ និងការបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា។

#### ១.៣.១. ការចាប់ខ្លួន

បន្ទាប់ពីសង្កេតឃើញថា អនីតិជនបានប្រព្រឹត្តបទល្មើស ឬសង្ស័យថាបានប្រព្រឹត្តបទល្មើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការចាប់ខ្លួនអនីតិជន និងរាយការណ៍ភ្លាមទៅកាន់ព្រះរាជអាជ្ញា ដើម្បីធ្វើការចាប់ខ្លួនអនីតិជននោះ ក្នុងគោលបំណងធ្វើការសាកសួរថាតើជននោះបានប្រព្រឹត្តបទល្មើស ឬមានជាប់ពាក់ព័ន្ធក្នុងការប្រព្រឹត្តបទល្មើសដែរឬទេ។ លក្ខណៈពិសេសនៃការចាប់ខ្លួនអនីតិជន គឺមន្ត្រីនគរបាលយុត្តិធម៌អាចចាប់ខ្លួនបានចំពោះអនីតិជនដែលមានអាយុ ១៤ (ដប់បួន) ឆ្នាំ រហូតដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ក្នុងករណីអនីតិជនបានប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ [16] ។ ប៉ុន្តែប្រសិនបើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៦(ដប់ប្រាំមួយ) ឆ្នាំវិញ ការចាប់ខ្លួននោះនឹងប្រព្រឹត្តទៅបានក្នុងករណីដែលអនីតិជនបានប្រព្រឹត្តបទមជ្ឈិមដោយចេតនា។

លើសពីនេះទៅទៀត ការចាប់ខ្លួនទាំងអស់ត្រូវតែធ្វើការរាយការណ៍ទៅដល់ព្រះរាជអាជ្ញាភ្លាម មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែជៀសវាងការធ្វើអោយអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត [17]។ ព្រមទាំងមិនត្រូវប្រើប្រាស់ខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែលសម្រាប់បង្ខំ ឬរារាំង

[15] មាត្រា១៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[16] មាត្រា១៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[17] មាត្រា១៥ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ឡើយលើកលែងតែបានប្រើប្រាស់គ្រប់មធ្យោបាយសម្រាប់ត្រួតត្រាផ្សេងៗរួចហើយ ឬប្រើប្រាស់គ្រប់មធ្យោបាយផ្សេងៗទៀតពុំសមស្របនឹងកាលៈទេសៈ ឬដើម្បីរារាំងសកម្មភាពដែលអនីតិជននោះអាចបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរលើខ្លួនឯង ឬលើបុគ្គលដទៃទៀត។ ក្នុងករណីប្រសិនបើមានការរារាំង ឬប្រើប្រាស់កម្លាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ ហើយបញ្ជាក់ពីមូលហេតុ និងកាលៈទេសៈដែលត្រូវប្រើប្រាស់កម្លាំង បន្ទាប់មកត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត។

ក្នុងការចាប់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់ពីសិទ្ធិមួយចំនួនទៅកាន់អនីតិជននោះដែលមានសិទ្ធិដូចជា ៖ [18]

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលមាន ឬគ្មានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងដោយមិនយកកម្រៃស្របតាមលក្ខខណ្ឌដូចមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ចាប់ពីដំណាក់កាលដំបូងនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់នៅគ្រប់ដំណើរការរឿងក្តីប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ ប្រសិនបើចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសាកសួរសាក្សី
- សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស និង
- សិទ្ធិផ្សេងៗទៀតដូចដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិជាធរមាន។

[18] មាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ទោះបីជាយ៉ាងណាក៏ដោយ ការចាប់ខ្លួនគួរតែអនុវត្តសម្រាប់វិធានការចុងក្រោយបំផុតប៉ុណ្ណោះ។ ការចាប់ខ្លួនត្រូវមានមូលហេតុត្រឹមត្រូវតាមច្បាប់ ទោះបីជាការចាប់ខ្លួននោះ ត្រូវធ្វើឡើងដោយដីកាចាប់ខ្លួនតាមភស្តុតាងស៊ីសង្វាក់ ឬតាមបទល្មើសជាក់ស្តែងក្តី[19]។

**១.៣.២. ការឆែកឆេរ**

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើបុគ្គលដែលជាអនីតិជនបាន។ ការឆែកឆេរខ្លួនបុគ្គលដែលធ្វើឡើងត្រូវតែជាភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើសពុំមានទំនាស់ ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយ លើកលែងតែករណីមិនអាចជៀសបាន។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ[20]។

**១.៣.៣. ការឃាត់ខ្លួន**

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឃាត់ខ្លួនទៅលើអនីតិជនបានប្រសិនបើគេជឿជាក់ថា អនីតិជននោះអាចរត់គេចខ្លួន ឬបំផ្លាញភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សីជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬមានបំណងក្នុងការការពារសុវត្ថិភាពអនីតិជននោះ។ ប៉ុន្តែការឃាត់ខ្លួននេះ គឺត្រូវអាចប្រព្រឹត្តបានចំពោះអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ រហូតដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំប៉ុណ្ណោះ។ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៦ (ដប់ប្រាំមួយ) ឆ្នាំ ការឃាត់ខ្លួនអាចប្រព្រឹត្តទៅបានប្រសិនបើអនីតិជននោះបានប្រព្រឹត្តបទមជ្ឈិមដោយចេតនាតែប៉ុណ្ណោះ ហើយការឃាត់ខ្លួនទាំងអស់នេះ ត្រូវធ្វើការរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម [21]។

លក្ខណៈពិសេសនៃការអនុវត្តការឃាត់ខ្លួនទៅលើអនីតិជននេះ ពីមន្ត្រីនគរបាលយុត្តិធម៌មិនត្រូវយកអនីតិជនដាក់បង្ហាញមុខជាជួរឡើយ ក្នុងករណីដែលគ្មានការយល់ព្រមជាមុនពីអនីតិជន ឬចាំបាច់ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី និងអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជននោះជាមុន។ ប្រសិនបើអនីតិជនមានការយល់ព្រម ត្រូវតែមាននូវកំណត់ហេតុជាលាយលក្ខណ៍អក្សរ ព្រមទាំងផ្តិតម្រាមដៃពីសំណាក់អនីតិជនផងដែរ[22]។ ការឃាត់ខ្លួននេះ អនីតិជនត្រូវតែដាក់ដោយឡែកពីនីតិជន និងតាមភេទ ហើយមិនត្រូវទទួលរងនូវទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង សម្លុតបំភិតបំភ័យ ឬទង្វើដែលធ្វើឲ្យមានការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬអំពើអមនុស្សធម៌ណាមួយ ដោយត្រូវស្របទៅតាមគោលការណ៍

[19] មាត្រា៣៨ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨

[20] មាត្រា១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[21] មាត្រា១៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា២៣ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

នៃសន្ធិសញ្ញាស្តីពីសិទ្ធិកុមារអន្តរជាតិ និងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សអន្តរជាតិ ព្រមទាំងលិខិតុបករណ៍នានា។ បើមិនដូច្នេះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី ។ មិនតែប៉ុណ្ណោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ចប់នូវការស៊ើបអង្កេតរបស់ខ្លួនឲ្យបានឆាប់រហ័ស និងលឿនបំផុតតាមដែលអាចធ្វើទៅបាន ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន ដែលរយៈពេលនៃការឃាត់ខ្លួន គឺត្រូវអាស្រ័យទៅតាមអាយុ និងប្រភេទនៃបទល្មើស (បទឧក្រិដ្ឋ ឬបទមជ្ឈិម) ។

ចំពោះអនីតិជនដែលមានអាយុ ១៤ ឆ្នាំ ដល់ក្រោម១៦ ឆ្នាំ ដែលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល៣៦ ម៉ោងឡើយ ។ ចំពោះអនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ដែលប្រព្រឹត្តបទឧក្រិដ្ឋ មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៤៨ ម៉ោងឡើយ ។ ចំពោះអនីតិជនដែលមានអាយុ ១៤ ឆ្នាំ ដល់ក្រោម១៦ ឆ្នាំ ដែលប្រព្រឹត្តបទមជ្ឈិម មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ២៤ ម៉ោងឡើយ។ ចំពោះអនីតិជនដែលមានអាយុ ១៦ឆ្នាំ ដល់ក្រោម១៨ ឆ្នាំ ដែលប្រព្រឹត្តបទមជ្ឈិម មិនអាចត្រូវបានគេឃាត់លើសពីរយៈពេល ៣៦ ម៉ោងឡើយ ។ ចំពោះអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ ពុំអាចត្រូវបានគេឃាត់ខ្លួនឡើយ។ ប្រសិនបើគ្មានតម្រុយនៃបទល្មើសដែលអនីតិជននោះបានប្រព្រឹត្តទៅ នគរបាលយុត្តិធម៌មិនអាចបន្តនូវរយៈពេលនៃការឃាត់ខ្លួនបាននោះទេ ដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការដោះលែងអនីតិជននោះទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាល ឬនីតិជនដែលទទួលខុសត្រូវលើអនីតិជន ដោយបញ្ជាក់នូវលក្ខខណ្ឌមួយចំនួនមុនការដោះលែងដូចជា តម្រូវអនីតិជននៅក្នុងផ្ទះក្នុងរយៈពេលណាមួយ តម្រូវឱ្យរាយការណ៍ដល់នគរបាលនូវពេលវេលាជាក់លាក់ណាមួយ ព្រមទាំងហាមមិនឲ្យអនីតិជនសេពគ្រឿងស្រវឹងផ្សេងៗ រួមបញ្ចូលទាំងហាមមិនឲ្យជួបជនរងគ្រោះ មិនឲ្យធ្វើដំណើរទៅកន្លែងណាមួយ ឬលក្ខខណ្ឌដែលសមស្របតាមស្ថានភាពមួយ។

### ១.៣.៤. ការស្តាប់ចម្លើយ

មុនពេលចាប់ផ្តើមនូវការស្តាប់ចម្លើយ ប្រសិនបើមានការស្នើសុំអនីតិជនអាចធ្វើការសន្ទនា ឬទំនាក់ទំនងជាមួយអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ច និងមេធាវី ជាលក្ខណៈឯកជន និងសម្ងាត់ ដែលមានរយៈពេល ៣០ (សាមសិប) នាទីមុនពេលស្តាប់ចម្លើយ លើកលែងតែជនទាំងនោះទាក់ទិនក្នុងរឿងជាមួយគ្នា[23] ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែប្រាប់ដល់អនីតិជនអំពីសិទ្ធិមូលដ្ឋានក្នុងនីតិវិធីដូចដែលមានចែងក្នុងមាត្រា៦ ដល់អនីតិជន ជាពិសេសគឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី។ លើសពីនេះទៅទៀត ការស្តាប់ចម្លើយត្រូវប្រព្រឹត្តទៅដោយមានវត្តមានមេធាវីដោយប្រើប្រាស់នីតិវិធីកុមារមេត្រីដែលមានលក្ខណៈឯកជន និងជាការសម្ងាត់។ រីឯអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុក

[23] មាត្រា២១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

បម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចមានសិទ្ធិក្នុងការផ្តល់ជំនួយដល់អនីតិជន និងចូលរួមស្តាប់ចម្លើយរបស់អនីតិជនផងដែរ។

ប៉ុន្តែមន្ត្រីនគរបាលយុត្តិធម៌អាចបដិសេធចំពោះការចូលរួមអ្នកទាំងនោះបានទេ ប្រសិនបើយល់ឃើញថាវត្តមានរបស់ពួកគេអាចធ្វើឱ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជន ហើយការបដិសេធនេះគឺត្រូវមានការពិគ្រោះយោបល់ជាមួយនឹងមេធាវីភ្នាក់ងារសង្គមកិច្ច ឬអនីតិជនផ្ទាល់។ បន្ទាប់ពីបញ្ចប់នូវការស្តាប់ចម្លើយភ្លាម អនីតិជន និងបុគ្គលដែលបានរៀបរាប់ខាងលើអាចអាន និងធ្វើការពិនិត្យកំណត់ហេតុនៃចម្លើយបាន។ លើសពីនេះទៅទៀត អនីតិជនក៏អាចធ្វើការសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុនោះ។ មិនតែប៉ុណ្ណោះអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចដែលវត្តមានត្រូវចុះហត្ថលេខា និងផ្តិតម្រាមដៃលើកំណត់ហេតុផងដែរ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រានេះត្រូវមានលក្ខណៈដាច់ខាត ដោយត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានការមោឃភាពនៃនីតិវិធីនេះ[24]។

## ផ្នែកទី២ ៖ ដំណាក់កាលអង្គការអយ្យការ

### ២.១. សមត្ថកិច្ចរបស់តំណាងអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនឹងអនីតិជន។ ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជនទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាត ឬមិនដាច់ខាតក្តី។ ហើយតំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជន ត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទាក់ទងទៅនឹងយុត្តិធម៌អនីតិជន[25]។

#### ២.១.១. ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

នៅពេលដែលទទួលបានសំណុំរឿងបន្តពីមន្ត្រីនគរបាលយុត្តិធម៌ហើយ តំណាងអយ្យការត្រូវត្រួតពិនិត្យសំណុំឯកសារ និងបណ្តឹងដែលបានទទួល ដើម្បីផ្ទៀងផ្ទាត់អាយុពិតប្រាកដរបស់អនីតិជន មុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ។

[24] មាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[25] មាត្រា២៤ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីដែលមានវិមតិសង្ស័យចំពោះអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកនូវអាយុពិតប្រាកដរបស់អនីតិជន។ ក្នុងករណីដែលការស៊ើបអង្កេតបឋមនោះមិនឈានដល់ការសន្និដ្ឋានអំពីអាយុពិតរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ[26]។

### ២.១.២. ការស្តាប់ចម្លើយរបស់អនីតិជន

ចំពោះនីតិវិធីនៃការស្តាប់ចម្លើយរបស់ព្រះរាជអាជ្ញា គឺមិនមានលក្ខណៈខុសប្លែកពីនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌នោះទេ ដោយព្រះរាជអាជ្ញាធ្វើការស្តាប់ចម្លើយរបស់អនីតិជន និងធ្វើការសន្និដ្ឋានទៅលើសំណុំរឿងនោះតាមគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ចំពោះអនីតិជន ពោលគឺមុនពេលនៃការស្តាប់ចម្លើយព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមអំពីសិទ្ធិដែលមានចែងក្នុងមាត្រា៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់នេះ ដោយប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជន។

មិនតែប៉ុណ្ណោះការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រីដែលត្រូវមានវត្តមានរបស់មេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងរបស់អនីតិជន។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ចូលរួមស្តាប់បាន ប្រសិនបើវត្តមានរបស់អ្នកទាំងនោះប៉ះពាល់ឧត្តមប្រយោជន៍របស់អនីតិជន ប៉ុន្តែត្រូវតែមានការពិគ្រោះជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជនជាមុនសិន។ ក្នុងករណីអវត្តមានជនណាមួយ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ ស្តាប់ចម្លើយ ហើយបញ្ជាក់អំពីមូលហេតុ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាមអនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាឲ្យមេធាវី ឬឪពុកម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់ អនីតិជន ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន។ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសេដ្ឋកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃលើកំណត់ហេតុ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្តិតម្រាមដៃលើ

[26] មាត្រា២៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

កំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ។ វិធាននេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេនឹងនាំឲ្យមានមោឃៈភាពនៃនីតិវិធី [27]។

## ២.២. សេចក្តីសម្រេចរបស់តំណាងអយ្យការ

### ២.២.១.ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជនអាយុក្រោម១៤ឆ្នាំ

ក្នុងករណីដែលអនីតិជនមានអាយុក្រោម ១៤ (ដប់បួន) ឆ្នាំ គិតត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស ព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងបញ្ជូនអនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាលវិញ។ លើសពីនេះទៅទៀត ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជនទៅកាន់មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន [28]។

### ២.២.២. អំណាចរបស់តំណាងអយ្យការក្នុងការបង្វែរ

តំណាងអយ្យការក៏មានអំណាចក្នុងការបង្វែរ ក្នុងករណីដែលអនីតិជនមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ បានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ដោយការបង្វែរនេះ ព្រះរាជអាជ្ញាត្រូវពិចារណាទៅលើការបង្វែរក្នុងជំពូកទី១០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន និងយកបទប្បញ្ញត្តិទាំងនោះមកអនុវត្ត។ ក្នុងករណីនេះ ព្រះរាជអាជ្ញាត្រូវសម្រេចផ្អាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ហើយបង្គាប់ប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាល ឬអ្នកទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលការគ្រប់គ្រងថែរក្សា។ ចំពោះករណីនេះ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន។

ព្រះរាជអាជ្ញាត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជន ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យ ដោយផ្អែកទៅលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ។ ប៉ុន្តែក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ព្រះរាជអាជ្ញាចេញដីកាសម្រេចបង្វែរជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យមានការបរាជ័យចំពោះការអនុវត្តផែនការបង្វែរនេះ និងពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី[29]។

[27] មាត្រា២៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[28] មាត្រា២៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[29] មាត្រា២៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ចំពោះការឲ្យដំណឹងអំពីការចោទប្រកាន់ ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅកាន់អនីតិជន ហើយប្រសិនបើសមស្របត្រូវជូនដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជន ដើម្បីឲ្យធ្វើការរៀបចំមធ្យោបាយការពារអនីតិជននោះ។ ដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានបញ្ញត្តថាប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថាអ្នកប្រព្រឹត្ត នោះមានសហការី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជាអនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញនូវដីកានៃការបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឱ្យដាច់ដោយឡែកពីគ្នាផងដែរ។

## ផ្នែកទី៣ ៖ ដំណាក់កាលស៊ើបសួរ

ដំណាក់កាលស៊ើបសួររបស់ចៅក្រមស៊ើបសួរ ជាដំណាក់កាលមួយដែលមានសារៈសំខាន់នៅក្នុងដំណើរការជម្រះក្តីនៃរឿងក្តីព្រហ្មទណ្ឌ ដែលចៅក្រមស៊ើបសួរធ្វើការប្រមូលនូវភស្តុតាងចាំចាច់ ដែលពាក់ព័ន្ធសម្រាប់សម្រេចសេចក្តីចំពោះការចោទប្រកាន់មុននឹងបិទការស៊ើបសួរ។ នៅក្នុងការស៊ើបសួរទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងអនីតិជន។ ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាពពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

### ៣.១. ការបើកការស៊ើបសួរ និងការបង្ហាញខ្លួនរបស់អនីតិជននៅពេលស៊ើបសួរ

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។ ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ ចៅក្រមស៊ើបសួរវិញ ត្រូវទុកពេលវេលាសមស្របឲ្យមេធាវីអាចពិនិត្យមើលសំណុំរឿង និងពិភាក្សាជាមួយអនីតិជន មុនពេលចាប់ផ្តើមសួរចម្លើយ ។

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរ។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។ វិធានការដែលបានបញ្ញត្តិនៅក្នុងមាត្រានេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នោះទេ នឹងនាំឲ្យមានមោឃភាពនៃនីតិវិធី[30]។

[30] មាត្រា៣៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.១.១. ការប្រាប់អំពីសិទ្ធិរបស់អនីតិជន

អនីតិជនគ្រប់រូបដែលជាជនជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាបានប្រព្រឹត្តបទល្មើស ត្រូវបានទទួលនូវសិទ្ធិជាមូលដ្ឋាននៅក្នុងដំណើរការនីតិវិធីពិសេស នៅក្នុងកិច្ចនៃការស៊ើបសួរដែលធ្វើឡើងដោយចៅក្រមស៊ើបសួរដូចតទៅ[31]៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានការឲ្យដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីតាមរយៈការជ្រើសរើស និងការចាត់តាំងដោយពុំយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិកៈមេធាវីចាប់ពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់ នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ ប្រសិនបើមានការចាំបាច់
- សិទ្ធិបង្ហាញភស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតឲ្យនៅក្រៅឃុំ
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានការត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាមួយនឹងស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីដែលអនីតិជននោះជាជនបរទេស
- សិទ្ធិផ្សេងៗដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តជាធរមាន។

[31]មាត្រា៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.១.២. ការស្តាប់ចម្លើយអនីតិជន

ចៅក្រមស៊ើបសួរត្រូវស្តាប់ចម្លើយអនីតិជនដោយផ្ទាល់ និងមានក្រឡាបញ្ជីជាជំនួយការ ។ ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជននិងភ្នាក់ងារសង្គមកិច្ច ។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យឪពុកម្តាយ ឬអាណាព្យាបាលអនីតិជនចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ហើយចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលអនីតិជន ឬអ្នកទំនុកបម្រុងអនីតិជន និងភ្នាក់ងារសង្គមកិច្ច។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាមអនីតិជន មានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃ។ ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬឪពុកម្តាយ ឬអ្នកអាណាព្យាបាលអនីតិជន ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានមានការស្នើសុំ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខាឬផ្តិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ[32]។

មួយវិញទៀតក្នុងករណីអវត្តមាន ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវីដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង។ ប្រភេទនៃការបន្ទាន់ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ពិសេសវត្តមាន ឬអវត្តមានរបស់មេធាវី មិនរារាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្នឡើយ[33]។

### ៣.១.៣. ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬការព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរគ្រឹះស្ថាន ឬនិយោជកអាចព្យួរការងារ ឬព្យួរការងាររហូតដល់មាន

[32] មាត្រា៣៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[33] មាត្រា៣៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សេចក្តីសម្រេចតុលាការជាស្ថាពរ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ[34]។

### ៣.២. អំណាចរបស់ចៅក្រមស៊ើបសួរ

#### ៣.២.១. អំណាចក្នុងការបង្វែរ

នៅពេលបានទទួលដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរ ហើយអនីតិជនដែលមានអាយុពី១៤(ដប់បួន) ឆ្នាំដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ដែលតំណាងអង្គការអយ្យការចោទប្រកាន់ថាបានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ចៅក្រមស៊ើបសួរត្រូវគិតជាបឋមពីការបង្វែរពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណស្ថានភាពអនីតិជន និង ត្រូវពិនិត្យលើលក្ខខណ្ឌអប្បបរមានៃការបង្វែរ ។

ក្នុងករណី ដែលបានបំពេញបានគ្រប់គ្រាន់នូវលក្ខខណ្ឌអប្បបរមានៃការបង្វែរចៅក្រមស៊ើបសួរមុននឹងសម្រេចចិត្តធ្វើការបង្វែរ ឬមិនបង្វែរត្រូវពិចារណាលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការបង្វែរ នៅពេលដែលយល់ឃើញថាត្រូវបង្វែរ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជននោះទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្វែរ ទោះបីផែនការបង្វែរត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជននិងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្វែរទទួលបានជោគជ័យដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបានបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ ។ ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្វែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ចឬចាត់វិធានការតាមនីតិវិធី[35] ។

[34] មាត្រា៣៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[35] មាត្រា៣៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.២.២. អំណាចក្នុងការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្ដោះអាសន្ន ជាវិធានការចុងក្រោយ ។ បន្ថែមលើបទប្បញ្ញត្តិស្ដីពីលក្ខខណ្ឌមូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែលប្រសិនបើមាន។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននៃការឃុំខ្លួនបណ្ដោះអាសន្ន។

ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជននោះជាបន្ទាន់ទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅឪពុកម្ដាយអ្នកអាណាព្យាបាលសម្រាប់អនីតិជន។ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលបានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ ក្នុងករណីដែលអនីតិជនគ្មានឪពុកម្ដាយ ឬអ្នកអាណាព្យាបាល មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការ ដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្ដឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន[36]។

### ៣.២.៣. អំណាចក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទប្រកាន់ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្ដីពីចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចជា ៖

[36] មាត្រា៣៩ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- ដាក់អនីតិជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ដាក់អនីតិជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- វិធានការផ្សេងទៀតដែលតុលាការយល់ឃើញថាសមស្រប[37]។

### ៣.២.៤. ការបង្គាប់ឲ្យដោះលែងឲ្យនៅក្រៅឃុំ

ចៅក្រមស៊ើបសួរ អាចបង្គាប់ដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលដោយគំនិតផ្តួចផ្តើមរបស់ខ្លួន តែត្រូវជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីសុំយោបល់ ហើយព្រះរាជអាជ្ញាត្រូវផ្តល់យោបល់ត្រឡប់មកវិញក្នុងរយៈពេលខ្លីបំផុត ។ក្នុងករណីបន្ទាន់ដែលចាំបាច់ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យដោះលែងអនីតិជនភ្លាម ដោយពុំចាំបាច់រង់ចាំយោបល់របស់ព្រះរាជអាជ្ញានោះទេ ឬទោះមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ។ ដោយត្រូវបញ្ជាក់ពីមូលហេតុបន្ទាន់នេះនៅក្នុងដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំរបស់ចៅក្រមស៊ើបសួរ។

ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅអ្នកតំណាងដែលច្បាប់បានកំណត់។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពនិងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។

ក្នុងករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ព្រះរាជអាជ្ញា អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងអនីតិជនអាចសុំឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានគ្រប់ពេលវេលា ។ មេធាវីអាចសុំដោះលែងអនីតិជនឲ្យនៅក្រៅឃុំបានដោយមានការយល់ព្រមពីអនីតិជន ។ ចៅក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ [38]។

---

[37] មាត្រា៤០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[38] មាត្រា៤១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

## ៣.៣. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីរបាយការណ៍ស្ដីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ច ផ្ដល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០(ដប់)ថ្ងៃនៃការធ្វើការ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម ៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- អនីតិជនដែលបានប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើអនីតិជនត្រូវចោទ។

ដីកាដំណោះស្រាយលើកលែងការចោទប្រកាន់ មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំទោះបីមានបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ ។ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅឲ្យឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្តដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។

ក្នុងករណីយល់ឃើញថា អនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំណួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ បើករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់មន្ទីរ ឬ ការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ[39] ។

[39] មាត្រា៤២ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៣.៤. ការប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្វែររបស់ចៅក្រមស៊ើបសួរព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន[40]។

## ផ្នែកទី៤ ៖ ដំណាក់កាលចៅក្រមជំនុំជម្រះ និងការជំនុំជម្រះ

### ៤.១. សមត្ថកិច្ចនៃចៅក្រមជំនុំជម្រះ

ការជំនុំជម្រះករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជនល្មើសនឹងច្បាប់ សមត្ថកិច្ចរបស់តុលាការជំនុំជម្រះក្តីនៃសាលាដំបូងរាជធានី ខេត្ត ដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជនជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។ ចំពោះសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីអនីតិជន ត្រូវមានសមូហភាពដោយមានចៅក្រម ៣ (បី)រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។ ចំពោះការជំនុំជម្រះបទលហុ ចំពោះរឿងក្តីអនីតិជន គឺមានតែចៅក្រមម្នាក់ដែលធ្វើការសម្រេចសេចក្តី [41] ។ តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាពជាពិសេសរឿងក្តីអនីតិជនដែលជាប់ឃុំខ្លួនបណ្តោះអាសន្ន។ មិនតែប៉ុណ្ណោះ ដើម្បីជាឧត្តមប្រយោជន៍សម្រាប់ការរង់ចាំការជំនុំជម្រះ តុលាការត្រូវពិចារណាដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព។ ចំពោះរឿងក្តីដែលត្រូវបានលើកពេលជំនុំជម្រះ ដូចគ្នាដែរតុលាការត្រូវពិចារណាអំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាពឡើងវិញ[42] ។

### ៤.២.នីតិវិធីមុនពេលសវនាការ

មុនពេលសវនាការ តុលាការចាំបាច់ត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ ប្រសិនបើរបាយការណ៍ដែលត្រូវពិនិត្យនោះពុំទាន់បានរៀបចំ ឬបើតុលាការយល់ឃើញថាពត៌មានដែលផ្តល់ឲ្យនោះមិនទាន់គ្រប់គ្រាន់នោះទេ តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំនិងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់ទៅតាមតម្រូវការជាក់ស្តែង[43]។

[40]មាត្រា៤៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[41] មាត្រា៤៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[42] មាត្រា៤៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[43] មាត្រា៤៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

### ៤.៣ ដំណើរការសវនាការ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។ មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ រួមមានអនីតិជនដែលបានប្រព្រឹត្តបទល្មើសជនរងគ្រោះ និងមេធាវី ព្រមទាំងភ្នាក់ងារសង្គមកិច្ច ។ ចំណែកឯឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជន អាចអនុញ្ញាតឲ្យចូលរួមក្នុងសវនាការបាន លើកលែងតែមានសំណូមពរពីអនីតិជនផ្ទុយពីនោះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះ មិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន[44]។

នៅក្នុងពេលសវនាការ តុលាការត្រូវរៀបចំឲ្យមានលក្ខណៈនីតិវិធីកុមារមេត្រី ។ ក្នុងកាលៈទេសៈពិសេសមេធាវីរបស់អនីតិជន បុគ្គលិកសង្គមកិច្ច ឬព្រះរាជអាជ្ញាអាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការផ្តល់ចម្លើយ[45] ។

រឿងក្តីអនីតិជន ជំនួយរបស់មេធាវីត្រូវតែមានដាច់ខាតនៅក្នុងសវនាការ បើគ្មានការជ្រើសរើសដោយអនីតិជនមេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃ តាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿងទៅឲ្យមេធាវីសម្រាប់រៀបចំការការពារ ។

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម[46] ៖

- សិទ្ធិបានដឹងអំពើដែលបានចោទប្រកាន់
- សិទ្ធិមានមេធាវីការពារ
- សិទ្ធិមានអ្នកបកប្រែភាសាមិនគិតកម្រៃ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោយមិនសមរម្យ
- សិទ្ធិបង្ហាញភស្តុតាង សិទ្ធិសុំសួរសាក្សី និងសិទ្ធិសុំកោះហៅសាក្សី
- សិទ្ធិប្តឹងជិតចិត្តចៅក្រមជំនុំជម្រះក្តី
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង

[44] មាត្រា៤៧ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[45] មាត្រា៤៨ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦
[46] មាត្រា៥១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិប្ដឹងឧទ្ធរណ៍ ។

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែងបង្ខិតបង្ខំ ឬ ការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាពឡើយ ។

ការសារភាពទទួលយកផែនការបង្វែរ មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាព ក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។ ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស[47] ។

### ៤.៤. ការឲ្យរួចផុតពីបទចោទ

បើក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្ដឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយអនីតិជន ហើយប្រគល់អនីតិជននោះឲ្យទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជន។

ប្រសិនបើក្នុងករណីតុលាការរកឃើញថា អនីតិជននោះពិតជាបានប្រព្រឹត្តបទល្មើសតុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្ដឹងរដ្ឋប្បវេណី ។ មួយវិញទៀតបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្ដឹង ឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាល ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀត ។ ហើយគ្រប់ករណីទាំងអស់ បើអនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះតុលាការសម្រេចបញ្ជូនអនីតិជននោះដើម្បីចាត់វិធានការសមស្របទៅតាមទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។

ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់កំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។

[47] មាត្រា៥៣ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំ ទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ[48] ។

### ៤.៥. ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬ នៅពេលសវនាការលើកក្រោយ ។ ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿង ។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ[49]។

### ៤.៦. អំណាចរបស់តុលាការក្នុងការបង្វែរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម តុលាការត្រូវពិចារណាជាបឋម ទៅលើការបង្វែរដូចមានចែងក្នុងជំពូកទី ១០ (ការបង្វែរ) នៃច្បាប់នេះ ។ បទមជ្ឈិមដែលមានស្ថានទម្ងន់ទោស អាចត្រូវបានយកមកពិចារណាអំពីការបង្វែរផងដែរ ។

ក្នុងករណីលក្ខខណ្ឌអប្បបរមាត្រូវបានបំពេញតុលាការត្រូវចេញសាលក្រមបង្អង់រឿងទុកសិន បន្ទាប់មកត្រូវ៖

- ពិគ្រោះយោបល់ជាមួយអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុងមេធាវី ភ្នាក់ងារសង្គមកិច្ច ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធផ្សេងទៀត
- រៀបចំផែនការបង្វែរ
- ឲ្យអនីតិជនចុះហត្ថលេខា ឬផ្តិតម្រាមដៃអនុវត្តផែនការបង្វែរ ។

ក្នុងករណីតុលាការសម្រេចបង្វែរបទប្បញ្ញត្តិក្នុងជំពូកទី១០ (ការបង្វែរ) នៃច្បាប់នេះត្រូវយកមកអនុវត្ត។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ។ ប្រសិនបើអនីតិជនកំពុងជាប់ឃុំ តុលាការត្រូវបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះទៅអ្នកតំណាងដែលច្បាប់បានកំណត់ ។

[48] មាត្រា៤៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[49] មាត្រា៥៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំ តុលាការត្រូវបញ្ជូនអនីតិជននោះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាពសង្គមរបស់អនីតិជន។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នេះ មន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យនូវផែនការបង្វែរ ដោយមានរបាយការណ៍បញ្ជាក់រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្វែរ តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ ក្នុងករណីការអនុវត្តផែនការបង្វែរទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្វែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្វែរ ទស្សនៈរបស់អនីតិជនអ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី[50] ។

[50] មាត្រា៥២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

# ជំពូកទី៣

# វិធានការអនុវត្តចំពោះអនីតិជនដែលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ

## ផ្នែកទី១ ៖ ការផ្តន្ទាទោស និងការអនុវត្តទោស

ការដាក់ទោស គឺជាផ្នែកមួយដ៏សំខាន់មួយ ដែលច្បាប់ត្រូវអនុវត្តចំពោះកុមារត្រូវតែខុសឆ្ងាយពីច្បាប់ដែលអនុវត្តចំពោះនីតិជន ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងថា ទោះបីកុមារត្រូវបានឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក្តី ការធ្វើទោសបែបនេះ ត្រូវតែធ្វើក្នុងលក្ខណៈមួយដែលលើកកម្ពស់ដល់ការធ្វើសមាហរណកម្មកុមារចូលទៅក្នុងសង្គមជាតិវិញ។ វិធីសាស្ត្រនៃការដាក់ទណ្ឌកម្មគ្រង់ៗត្រូវបានហាមឃាត់ហើយការដាក់ទណ្ឌកម្មណាមួយ ត្រូវតែសមាមាត្រ មិនត្រឹមតែចំពោះបទល្មើសប៉ុណ្ណោះទេ តែថែមទាំងសមាមាត្រទៅនឹងប្រវត្តិ និងកាលៈទេសៈរបស់កុមារម្នាក់ៗទៀតផង[51] ។

### ១.១. ការផ្តន្ទាទោសចំពោះអនីតិជន

ជាទូទៅការផ្តន្ទាទោសចំពោះអនីតិជន រួមមានទាំងប្រភេទនៃទោសដែលអាចអនុវត្តបានដូចជា (ការផាកពិន័យ ការព្យួរទោសសាកល្បង ឬការដាក់ក្នុងពន្ធនាគារ) ក៏ដូចចំនួនអតិបរមា ឬរយៈពេលអតិបរមានៃទោសនោះ (ដូចជារយៈពេលជាប់ពន្ធនាគារ ២០ឆ្នាំ) ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានធ្វើការលុបចោលលើបទប្បញ្ញត្តិទាំងនេះ ដោយចែងអំពីគោលការណ៍ដាក់ទោសខុសៗគ្នា មានដូចជា ជម្រើសនៃការដាក់ទោសដោយមិនឃុំឃាំងរួមទាំងឆន្ទានុសិទ្ធិឬភាពបត់បែនដែលមានលក្ខណៈកាន់តែធំធេងនៅពេលធ្វើសេចក្តីសម្រេចអំពីចំណាត់ការដ៏សមស្របបំផុត។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងរួមបញ្ចូលដូចជា គោលការណ៍ជាមូលដ្ឋាន ឬកត្តានានា សម្រាប់ធ្វើការពិចារណានៅពេលធ្វើសេចក្តីសម្រេចអំពីចំណាត់ការដ៏សមស្របបំផុត ត្រូវចែងឲ្យបានច្បាស់ ហើយជាពិសេសការប្រើប្រាស់ការឃុំខ្លួនអនីតិជនត្រូវបានកំហិត លើកលែងតែចំពោះបទល្មើសធ្ងន់ធ្ងរដែលត្រូវបានចែងជាពិសេស គឺការដកហូតសេរីភាព ត្រូវបើប្រាស់ជាវិធានការណ៍ចុងក្រោយបំផុតក្នុងរយៈពេលសមស្រប និងខ្លីបំផុតត្រូវតែចែងឲ្យច្បាស់ដែលចំពោះបញ្ហានេះត្រូវតម្រូវឲ្យមានការពិចារណាដោយគិតពីឧត្តមប្រយោជ៍របស់អនីតិជន ។ តែផ្ទុយទៅវិញ ការដាក់ទណ្ឌកម្មលើរូបរាងកាយចំពោះអនីតិជនត្រូវបាន ហាមឃាត់ប៉ុន្តែការដាក់ទណ្ឌកម្មនេះអាចធ្វើទៅបាន លុះត្រាតែមានច្បាប់ចែងឲ្យបានច្បាស់លាស់ជាមុនសិន ។ ទោះបីមានការដាក់ទោសយ៉ាងណាក៏ដោយទោសប្រហារជីវិត ឬការឃុំខ្លួនមួយជីវិត ត្រូវបានហាមឃាត់ក្នុងការយកមកអនុវត្តចំពោះអនីតិជន ។ ដោយយល់ឃើញថាបញ្ហាក្នុងការផ្តន្ទាទោសដល់អនីតិជនដែលបណ្តាលឲ្យមានការបង្អាក់នូវភាពរីកចម្រើនដែលអាចនឹងជះឥទ្ធិពលដល់សង្គមជាតិតែប៉ុណ្ណោះទេ ចំណែក

[51] សៀវភៅសារណា យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌរៀបរៀងដោយសាំង រដ្ឋា និង រ៉ា សម្បត្តិ

វិស័យអប់រំ ដែលជាកត្តាមួយសំខាន់ដែលអាចនាំឲ្យខ្វះខាតនូវធនធានមនុស្ស ជំនាន់ក្រោយៗទៀត មិនត្រឹមការផ្តន្ទាទោសចំពោះអនីតិជនធ្វើឲ្យមានការប៉ះពាល់ដល់ការអភិវឌ្ឍន៍ខ្លួនរបស់អនីតិជន។ តុលាការគ្រប់លំដាប់ថ្នាក់ ត្រូវពិនិត្យពិចារណាលើ កាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈនៃជនជាប់ចោទដូចជា ពិការភាព គ្មានទីជម្រកភាពក្រីក្រ បញ្ញាស្មារតីខ្សោយ មិនទទួលបានការអប់រំរៀនសូត្រ គ្មានការគ្រប់គ្រង ត្រូវបានគេបោះបង់ចោល មានការបង្ខិតបង្ខំពីបុគ្គលណាមួយដែលមានអំណាចលើអនីតិជននោះ ធ្លាប់បានជួបប្រទះហេតុការណ៍ប៉ះទង្គិចផ្លូវចិត្ត មិនធ្លាប់បានប្រព្រឹត្តបទល្មើស មានការអភ័យទោសពីសំណាក់ជនរងគ្រោះ ភាពមិនប្រក្រតីពីកំណើតរបស់កុមារ គ្មានសញ្ញាបង្ហាញពីការគំរាមកំហែងធំដុំដល់សង្គម ឬបរិយាកាសគ្រួសារដែលរំលោភបំពាន។ បទល្មើសរបស់អនីតិជនប្រព្រឹត្តឡើងដោយសារមានការប្រមាថ ឬការរើសអើងពីបុគ្គលណាមួយមកលើខ្លួនជាអាទិ៍ ពូជសាសន៍ សាសនា ពិការភាព សញ្ជាតិ អាយុ ភេទ ឬនិន្នាការនយោបាយ កត្តាសម្រាប់ផ្សេងៗដែលតុលាការយល់ឃើញគប្បីលើកយកពិចារណា ។

## ១.២. ការអនុវត្តទោសចំពោះអនីតិជន

អនុសញ្ញាស្តីពីសិទ្ធិកុមារ និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិជនដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ចែងអំពីក្រមដែលមានលក្ខណៈពេញលេញនៃសិទ្ធិកុមារដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។ ហេតុនេះហើយត្រូវចែងឲ្យបានច្បាស់លាស់អំពីគោលបំណង ឬវត្ថុបំណងនៃការឃុំដែលផ្តោតលើការស្តារនីតិសម្បទាមិនមែនជាការដាក់ទណ្ឌកម្ម។ បើយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន ដែលបានផ្តល់ឲ្យនូវអនីតិជនដែលបានផ្តន្ទាទោស ត្រូវស្ថិតនៅជាលក្ខណៈជាជនដែលត្រូវទទួលនូវគោលការណ៍ស្តារនីតិសម្បទាតែប៉ុណ្ណោះ កត្តានេះហើយទើបធ្វើឲ្យមានការសម្រេចសេចក្តីថា តុលាការគ្រប់លំដាប់ថ្នាក់អាចសម្រេចប្រគល់ទណ្ឌិតជាអនីតិជន ដែលត្រូវបានផ្តន្ទាទោសទៅលើមណ្ឌលឃុំនីតិសម្បទារាជធានី-ខេត្តណាមួយ ដែលសមស្របប្រសិនបើមានការសំណូមពរពីទណ្ឌិតជាអនីតិជន។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨(ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន នឹងកំពុងអនុវត្តទោសនៅក្នុងមណ្ឌលឃុំនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលឃុំនីតិសម្បទាបន្តរហូតដល់អាយុក្រោម ២៤ (ម្ភៃបួន) ឆ្នាំ ។ នៅពេលទណ្ឌិតឈានចូលអាយុ ២៤ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជននិងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

### ១.៣. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន

ដើម្បីអនុវត្តបានចំពោះអនីតិជន យើងត្រូវធ្វើការតែងតាំងអាជ្ញាធរទទួលបន្ទុកធ្វើអធិការកិច្ចជាប្រចាំ និងតាមពេលវេលាកំណត់ក្នុងគ្រប់ទីកន្លែងឃុំខ្លួនទាំងអស់ រួមមានការចូលសួរសុខទុក្ខដោយសេរី និងមិនចាំបាច់ជូនដំណឹងឲ្យដឹងជាមុននោះទេ ។ តែផ្ទុយទៅវិញយោងតាមមាត្រា ១៦០នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ នៃព្រះរាជាណាចក្រកម្ពុជា បាននិយាយថាក្នុងករណីដែលតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចជា ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។ ដូចជាករណីបទឃាតកម្មធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ប៉ុន្តែចំពោះជនល្មើសជាអនីតិជនអាយុចន្លោះពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ទោសដាក់ពន្ធនាគារគឺត្រូវកាត់បន្ថយពាក់កណ្តាល គឺមកត្រឹមតែពី ៥ឆ្នាំ ទៅ ៧ឆ្នាំកន្លះវិញ ។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតអតិបរមា ត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល[52] ។

តែផ្ទុយទៅវិញចំពោះបទប្បញ្ញត្តិស្តីពីទោស ដែលអនុវត្តលើអនីតិជននៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពុំមានចែងដែលទាក់ទងនឹងចំណុចដែលកំណត់ទោសដែលអាចអនុវត្តចំពោះអនីតិជននោះទេ ។ តែផ្ទុយទៅវិញ រាល់ទោសដែលអនុវត្តចំពោះអនីតិជន ត្រូវអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

## ផ្នែកទី២ ៖ សមត្ថកិច្ចគ្រប់គ្រងអនីតិជន

### ២.១. មណ្ឌលយុវនីតិសម្បទា

ការឃុំខ្លួនអនីតិជន ធ្វើឡើងក្នុងគោលបំណងនៃការស្តារនីតិសម្បទាជាអាទិ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។ មន្ត្រីមណ្ឌលយុវនីតិសម្បទាដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាពបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និង

[52] មាត្រា១៦០ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩

វិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។ ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទា នៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ។

សម្រាប់ការគ្រប់គ្រងអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នាគឺ ៖

- ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហរណកម្ម ។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យយុវនីតិសម្បទា ។ បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ទីទទួលបន្ទុក វិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌[53]។ ចំណែកឯការរក្សាអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាដូចជា អនីតិជនត្រូវដាក់ដោយឡែកពីនីតិជននៅក្នុងអាគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និង ផ្លូវចិត្តរបស់អនីតិជន អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នានៅអាគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជម្ងឺឆ្លង ។

## ២.២. សិទ្ធិជាមូលដ្ឋានរបស់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អនីតិជនដែលជាប់ឃុំនៅក្នុងមណ្ឌលយុវនីតិសម្បទាទាំងអស់ ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- សិទ្ធិទទួលបានការសិក្សាអប់រំ
- សិទ្ធិរួចផុតពីការធ្វើឬទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ

[53] មាត្រា៧៧ នៃនៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

- សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជនសិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ចសិទ្ធិផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្ដល់ដំណឹងទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ អ្នកទំនុកបម្រុង និងមេធាវី
- សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខ ជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្តិ និងសិទ្ធិផ្សេងទៀត[54]។

## ២.៣. ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជនគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្ដល់សេវាជាបន្ទាន់ដល់អនីតិជន ។
- ប្រមូលព័ត៌មានស្ដីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ហាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្ដល់របាយការណ៍ និងយោបល់ស្ដីពីប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រមអយ្យការនិងតុលាការ ។
- ផ្ដល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធីរៀបចំ និងផ្ដល់ផែនការបង្វែរដល់អាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យ និងសម្រេចផ្ដល់សេវាស្ដារនីតិសម្បទា និងធ្វើសមាហរណកម្មអនីតិជនភារកិច្ចចាំបាច់ផ្សេងទៀតដែល កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច [55]។

[54] មាត្រា៨០ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

[55] មាត្រា១១ នៃច្បាប់ស្ដីពីយុត្តិធម៌អនីតិជនឆ្នាំ២០១៦

# សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានយើងបានធ្វើការបកស្រាយប្រធានបទខាងលើយ៉ាងល្អិតល្អន់រួចមក ចំណុចសំខាន់ៗជាច្រើនដែលទាក់ទងជាមួយ ការទទួលខុសត្រូវព្រហ្មទណ្ឌអនីតិជនតាមច្បាប់យុត្តិធម៌អនីតិជន ត្រូវបានស្រាយបំភ្លឺកាន់តែច្បាស់ ។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ច្បាប់តម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ច ត្រូវតែអនុវត្តយ៉ាងដាច់ខាតទៅតាមនីតិវិធីទាំងឡាយ និងត្រូវគោរពតាមឲ្យបានហ្មត់ចត់ ក្នុងគោលបំណងដើម្បីធ្វើការពិនិត្យ ស្រាវជ្រាវឲ្យឃើញពីនត្ថិភាព ឬការកើតមានឡើងនូវបទល្មើសដែលប្រព្រឹត្តឡើងដោយអនីតិជន ។ ជាងនេះទៅទៀត ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានផ្តល់អាទិភាព និងការពារអនីតិជនយ៉ាងខ្លាំងក្លាបំផុត ដែលក្នុងនោះរួមមានជាអាទិ៍ សិទ្ធិជាមូលដ្ឋានក្នុងកិច្ចនៃនីតិវិធីនៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស តាំងពីដំណាក់កាលនគរបាលយុត្តិធម៌រហូត ដល់ដំណាក់កាលជំនុំជម្រះដែលមានដូចជាសិទ្ធិមានមេធាវីក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ខ្លួន និងការសន្មតជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ ។ បន្ថែមពីនេះទៀត បើទោះបីជាអនីតិជនពិតជាបានប្រព្រឹត្តបទល្មើសពិតមែនក៏ដោយ តែច្បាប់បានផ្តល់នូវសិទ្ធិអំណាចដល់អនីតិជននោះយ៉ាងធំទូលាយ ដូចជាយន្តការនៃបង្វែរអនីតិជនចេញពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌ ដោយការប្រគល់អនីតិជនទៅអ្នកមានអំណាចមេបា ឬអ្នកដែលមាននីតិសម្បទាក្នុងការគ្រប់គ្រងអនីតិជន នៅក្នុងករណីអនីតិជននោះមិនទាន់គ្រប់អាយុដើម្បីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ លើសពីនេះទៅទៀត យន្តការនៃការបង្វែរនេះបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់អនីតិជនដូចជា បានធ្វើឲ្យអនីតិជននោះបានយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះ ធ្វើការកែប្រែកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអ្វីដែលសំខាន់នោះ គឺមិនមានការធ្វើការដកហូតនូវសិទ្ធិសេរីភាព ឬឃុំឃាំងអនីតិជនក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

ម្យ៉ាងវិញទៀត ប្រសិនបើអនីតិជននោះបានដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌហើយនោះមានយន្តការផ្សេងទៀតដូចជា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការដោះលែងឲ្យនៅក្រៅឃុំដែលនីតិវិធីទាំងនេះ បានផ្តល់សិទ្ធិដល់អនីតិជនយ៉ាងខ្លាំង ។ មានន័យថាទោះបីជាបានប្រព្រឹត្តបទល្មើសមែនក៏ដោយ ក៏ខ្លួនមិនត្រូវបានដកហូតនូវសិទ្ធិសេរីភាពនោះទេ ហើយខ្លួនអាចប្រើប្រាស់នូវសិទ្ធិដែលខ្លួនធ្លាប់មានពីមុនបាន ប៉ុន្តែអាចមាននៅពេលដែលមានការករណីខ្លះមានសិទ្ធិមួយចំនួនមិនអាចត្រូវបានអនុញ្ញាតឲ្យប្រើផងដែរបង្គាប់បញ្ជាពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងដើម្បីការពារនូវប្រយោជន៍របស់អនីតិជន ឬ បង្ការកុំឲ្យមានបទល្មើសថ្មីកើតមានឡើងទៀត និងជាពិសេសនោះគឺការពារប្រយោជន៍សង្គមទាំងមូល ។ ប៉ុន្តែប្រសិនបើក្នុងករណីអនីតិជនមិនបាន អនុវត្តតាម ឬ ប្រតិបត្តិតាមឲ្យបានត្រឹមត្រូវទៅតាមការបង្គាប់បញ្ជារបស់

អាជ្ញាធរមានសមត្ថកិច្ចនោះនឹងត្រូវមានទណ្ឌកម្មផ្សេងៗទៀតនិងត្រូវយកមកអនុវត្តចំពោះខ្លួនដូចជា ការយកមកឃុំខ្លួនបណ្តោះអាសន្នជាដើម ។ ចំពោះការអនុវត្តទោសរបស់អនីតិជន មានលក្ខណៈពិសេសខុសពីនីតិជនផងដែរ នៅពេលដែលតុលាការប្រកាសទោសឲ្យជាប់ពន្ធនាគារ ទោសរបស់អនីតិជនស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុតខុសពីនីតិជន ។ លើសពីនេះទៅទៀត អនីតិជនមិនបានដាក់នៅក្នុងពន្ធនាគារនោះទេ ដែលផ្ទុយពីច្បាប់ស្តីពីពន្ធនាគារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។ មានន័យថា រាល់បុគ្គលគ្រប់រូបៗដែលមានសាលក្រម ឬសាលដីកា ដែលត្រូវបានតុលាការធ្វើការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារជាស្ថាពរ និងត្រូវយកមកអនុវត្តទោសនៅក្នុងពន្ធនាគារទាំងអស់ ។ ប៉ុន្តែផ្ទុយទៅវិញ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ អនីតិជនដែលបានប្រព្រឹត្តបទល្មើសយកមកធ្វើការរក្សាទុកក្នុងមណ្ឌលយុវនីតិសម្បទា ដោយត្រូវដាក់អនីតិជននោះដាច់ដោយឡែកពីនីតិជន ហើយនៅក្នុងអគារដាច់ដោយឡែកទៅតាម ភេទ ប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។

# អនុសាសន៍

បើទោះបីជាអនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានតុលាការធ្វើផ្តន្ទាទោសតាមរយៈការដាក់ក្នុងមណ្ឌលយុវនីតិសម្បទា ឬមានទណ្ឌកម្មផ្សេងទៀតត្រូវបានច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិបានផ្តល់ឲ្យនូវសិទ្ធិឲ្យយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ពិតមែន ដូចជា (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩, ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧, អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ផ្សេងៗទៀត ជាពិសេសនោះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាច្បាប់ពិសេសដែលអនុវត្តចំពោះតែអនីតិជនដែលបានប្រព្រឹត្តបទល្មើសណាមួយតែប៉ុណ្ណោះ)។ ប៉ុន្តែផ្ទុយទៅវិញភាពខ្វះខាតមួយចំនួននៅតែមានផងដែរ។ បើទោះបីជាអនីតិជនជាប់សង្ស័យថាបាន ឬមិនបានប្រព្រឹត្តត្រូវតែអនុវត្តដោយ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវឲ្យស្ថាប័នមានសមត្ថកិច្ចគោរពតាមនីតិវិធីទាំងឡាយ ដែលបានចែងឲ្យបានហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលប្រព្រឹត្តដោយអនីតិជន ។ ដោយហេតុថា បទល្មើសទាំងនោះអាចនាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ខាតបង់ពេលវេលា និងការសិក្សា។ បើយោងតាមច្បាប់កំពូល គឺរដ្ឋធម្មនុញ្ញដែលបានកំណត់ទុកជាមុននូវគោលការណ៍មួយដ៏សំខាន់ គឺគោលការណ៍សច្ចធារណ៍នៃនិរទេសឬគោលការណ៍សន្មតជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ។ ការបង្ក្រាបបទល្មើស ឬបង្ការកុំឲ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជននោះ រដ្ឋគប្បីមានវិធានការឲ្យបានច្បាស់លាស់ និងយ៉ាងជាក់លាក់បំផុត ដែលតម្រូវឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធមួយចំនួនដែលរួមមានរាជរដ្ឋាភិបាលស្ថាប័នមានសមត្ថកិច្ចតុលាការ និងប្រជាពលរដ្ឋដោយផ្ទាល់តែម្តង។ បន្ថែមពីនេះទៀត ត្រូវមានការអប់រំអំពីបញ្ហាផ្លូវច្បាប់ឲ្យមានច្រើនធ្វើការផ្សព្វផ្សាយតាមរយៈកាសែតទស្សនាវដ្តី ទូរទស្សន៍ និងបណ្តាញសង្គមមួយចំនួន ដែលជាហេតុនាំឲ្យប្រជាជនបានយល់ដឹងពីច្បាប់និងអាចទប់ស្កាត់មិនឲ្យមានការកើតឡើង នៃចំនួនបទល្មើស។

ម្យ៉ាងវិញទៀតកត្តាគ្រួសារ ក៏ជាចំណែកមួយក្នុងការទប់ស្កាត់អនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសផងដែរមានន័យថានៅពេលដែលគ្រួសារមិនដែលបានបង្ហាត់បង្រៀនកូននិងពន្យល់បន្ថែមពីបញ្ហាផ្លូវច្បាប់ ចំពោះកូនថែមទាំងតែងតែមានអំពើហិង្សាក្នុងគ្រួសារច្រើននោះជាហេតុនាំឲ្យកូនយកគម្រូតាម ។ ដូចនេះសមាជិកក្នុងគ្រួសារ ត្រូវតែមានភាពស្និទ្ធស្នាលចំពោះកូន ហើយពួកគាត់ត្រូវតែបង្ហាត់បង្រៀនឲ្យកូនធ្វើជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ និងត្រូវធ្វើការពន្យល់ពីបញ្ហាផ្លូវច្បាប់ចំពោះកូនរបស់ខ្លួនផងដែរថាតើអំពើនេះ ឬអំពើនោះត្រូវបានច្បាប់ហាមឃាត់ ហើយបើសិនបានធ្វើខុសនោះនឹងត្រូវមានទណ្ឌកម្មយកអនុវត្តចំពោះខ្លួន។ បើទោះបីជាច្បាប់ស្តីពីយុត្តិធម៌អនីតិជន តម្រូវឲ្យស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្តីអនីតិជន ដែលបាន

ប្រព្រឹត្តបទព្រហ្មទណ្ឌ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់នេះក៏ពិតមែន តែដោយសារតែច្បាប់នេះនៅមានចំណុចមួយចំនួនមិនអនុវត្តបានពេញលេញនៅឡើយ ។គួរកត់សម្គាល់ថា នៅក្នុងការអនុវត្តជាក់ស្ដែង នៅក្នុងស្ថាប័នដែលទទួលបន្ទុកចាត់ការអនីតិជននេះក៏ឃើញមាននូវចំណុចគប្បីធ្វើការកែតម្រូវមួយចំនួនដូចជា ការជំនុំជម្រះអនីតិជនជាសាធារណៈ រាល់ការបង្វែរនៅមិនទាន់អាចអនុវត្តបានឲ្យពេញលេញនៅឡើយ ករណីខ្លះមិនមានការបំបែកសំណុំរឿងនៅឡើយនោះទេគឺធ្វើការជំនុំជម្រះអនីតិជនជាមួយនឹងនីតិជនតែម្ដង ហើយនៅតាមអង្គភាពនគរបាលខ្លះ ពិសេសនៅតាមបណ្ដាខេត្ត ឬស្រុកមួយចំនួនមិនទាន់មានការិយាល័យមេធាវី ឬអង្គការជំនួយផ្នែកច្បាប់ ដើម្បីចាំជួយផ្ដល់ជំនួយផ្នែកច្បាប់តាមរយៈមេធាវីដោយមិនយកកម្រៃនោះទេ។

ជាចុងក្រោយសម្រាប់ទស្សនៈរបស់ក្រុមយើងខ្ញុំយល់ឃើញថា ការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌អនីតិជនចែងយ៉ាងច្បាស់អំពីការដាក់ទណ្ឌកម្ម និង ការអនុវត្តនីតិវិធី វិធានទាំងបួនរួមមាន វិធានការតាមដាន វិធានការអប់រំ វិធានការការពារ និង វិធានការឧបត្ថម្ភ។ ផ្ទុយទៅវិញប្រសិនបើតុលាការយល់ឃើញថា កាលៈទេសៈរបស់បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ នោះមានន័យថា អនីតិជនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដែលតុលាការត្រូវប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះ។ ជាក់ស្ដែង ការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌយើងអាចយោងតាម ទោសព្រហ្មទណ្ឌដែលទោសនោះត្រូវអនុវត្តពាក់កណ្ដាលនៃទោសរបស់នីតិជន។

ដូចនេះ រដ្ឋាភិបាលត្រូវតែពង្រឹងវិស័យយុត្តិធម៌ សម្រាប់អនីតិជនព្រោះនៅមានភាពខ្វះចន្លោះច្រើនយុត្តិធម៌អនីតិជន ជាពិសេសការអនុវត្តច្បាប់ក្នុងដំណើការរឿងក្ដីឲ្យល្អប្រសើរតាំងពីដំណាក់កាលដំបូងរហូតដល់ការអនុវត្តទោសចប់របស់អនីតិជន ព្រោះដើម្បីការពារអនីតិជននូវសេចក្ដីថ្លៃថ្នូរ កិត្តិយស និងឧត្តមប្រយោជន៍អនីតិជនដែលបានប្រព្រឹត្តបទល្មើសឲ្យបានសុក្រឹត្យភាពកុំឲ្យមានការអនុវត្តខុសពីនីតិវិធី ដែលមានចែងក្នុងច្បាប់។

# ឯកសារយោង

## ក. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ១៩៩៣
- ច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៦/០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម១១០៩ / ០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/ រកម/០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨
- អនុសញ្ញាស្តីពីកុមារ ។

## ខ. សៀវភៅ និងស្នាដៃនិពន្ធ

- លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, ២០១៣-២០១៤, នីតិវិធីព្រហ្មទណ្ឌ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។
- វចនានុក្រមសម្តេចសង្ឃជួនណាត
- សៀវភៅសារណា ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនរៀបរៀងដោយណែម យ៉ុងអី និងជា ស្រីល័ក្ខ
- សៀវភៅសារណា យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌរៀបរៀងដោយសាំង រដ្ឋា និង រ៉ា សម្បត្តិ។

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- ឧបសម្ព័ន្ធទី១ កំណត់ហេតុសួរចម្លើយ
- ឧបសម្ព័ន្ធទី២ ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ
- ឧបសម្ព័ន្ធទី៣ ទម្រង់នៃដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន
- ឧបសម្ព័ន្ធទី៤ ដីកាសន្និដ្ឋានស្ថាពរ
- ឧបសម្ព័ន្ធទី៥ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន
- ឧបសម្ព័ន្ធទី៦ ដីកាលើកលែងចោទប្រកាន់
- ឧបសម្ព័ន្ធទី៧ ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ
- ឧបសម្ព័ន្ធទី៨ សាលក្រមរបស់សាលាដំបូងរាជធានីភ្នំពេញ

# ឧបសម្ព័ន្ធទី១
# កំណាត់ហេតុសួរចម្លើយ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**********

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ

# កំណត់ហេតុសួរចម្លើយ

សំណុំរឿងព្រហ្មទណ្ឌលេខ: ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥

ឆ្នាំពីរពាន់ដប់ប្រាំ ខែតុលា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួន និងសាមសិបនាទីព្រឹក។

**យើង** **ព្រះរាជអាជ្ញារង អមសាលាដំបូងរាជធានីភ្នំពេញ** ដោយមាន លោកស្រី ជាក្រឡាបញ្ជីអមផង បានសួរកត់យកចម្លើយរបស់ឈ្មោះ ភេទប្រុស <u>អាយុ ១៥ឆ្នាំ</u> ជនជាតិខ្មែរ មុខរបរដឹកអេតចាយ មានទីលំនៅកំណើត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង និងទីលំនៅបច្ចុប្បន្ននៅ ភូមិស្វាយតាអុក សង្កាត់ភលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ (រស់) ម្តាយឈ្មោះ (ស្លាប់) ជា<u>អនីតិជន</u> ទោសពីមុនគ្មាន។ ដោយមានបងស្រីបង្កើត ឈ្មោះ ចូលរួមស្តាប់ចម្លើយ ។

សួរ.ចម្លើយ៖ ខ្ញុំបាទសុំជម្រាបជូនថា ខ្ញុំបាទអាចឆ្លើយដោយខ្លួនឯងបាន ដោយពុំចាំបាច់មានវត្តមានមេធាវីទេ។

សួរ.ចម្លើយ៖ ចំពោះចម្លើយដែលឆ្លើយនៅចំពោះមុខសមត្ថកិច្ចពិតជាចម្លើយរបស់ខ្ញុំបាទមែន ដូច្នេះសុំរក្សាទុកនូវខ្លឹមសារទាំងស្រុងដដែល។

សួរ.ចម្លើយ៖ បានជាសមត្ថកិច្ចឃាត់ខ្លួនខ្ញុំដោយសារ នៅវេលាម៉ោងប្រហែល ០៥ល្ងាច ថ្ងៃទី ០៨.១០.២០១៥ ខ្ញុំបាទពិតជាបានអោយម៉ូតូមួយគ្រឿងម៉ាក C100 ភូរ៉េ ជ្រើស ពណ៌ក្រហម ទៅឈ្មោះ ខ្ញុំយកជិះទៅធ្វើសកម្មភាពឆក់ទ្វាផ្ទះគេចូលលួចទូដែកប្រាកដមែន។ ប៉ុន្តែខ្ញុំបាទពុំបានចូលរួមទៅធ្វើសកម្មភាពលួចជាមួយពួកគាត់ទេ។ លុះព្រឹកឡើងថ្ងៃទី ០៩.១០.២០១៥ វេលាម៉ោងប្រហែល ០៧ព្រឹក ឈ្មោះ បានទូរសព្ទហៅខ្ញុំទៅផ្ទះគាត់នៅខាងក្រោយវត្តច្បារអំពៅ មកយកម៉ូតូវិញ និងបានអោយប្រាក់មកខ្ញុំចំនួន ០១លានរៀល រួចខ្ញុំក៏វិលមកផ្ទះវិញ។,

សួរ.ចម្លើយ៖ រហូតដល់ស្អែកឡើងថ្ងៃទី ១០.១០.២០១៥ វេលាម៉ោងប្រហែល ១១ថ្ងៃត្រង់ ខណៈពេលខ្ញុំបាទកំពុងមើលឈ្មោះ និងឈ្មោះ លេងហ្គេម ស្រាប់តែសមត្ថកិច្ចមកដល់ឃាត់ខ្លួនខ្ញុំបាទ និងឈ្មោះ តែម្តង ចំនែកឈ្មោះ បានរត់គេចខ្លួនបាត់។

សួរ.ចម្លើយ៖ ខ្ញុំបាទប្រើប្រាស់ថ្នាំញៀនប្រភេទម៉ាទឹកកក។

សួរ.ចម្លើយ៖ ដូច្នេះខ្ញុំបាទសុំសំណូមពរដល់តុលាការមេត្តាជួយរកយុត្តធម៌ដល់រូបខ្ញុំបាទផង ព្រោះខ្ញុំបាទពុំបានចូលរួមធ្វើសកម្មភាពលួចជាមួយគេទេ។

ចំណាំខ្ញុំអស់តែប៉ុណ្ណេះ។

ឈប់សួរ បានអានអោយស្តាប់ សាម៉ីខ្លួនបានឆ្លើយថាត្រឹមត្រូវហើយ ហើយសុខចិត្តចុះហត្ថលេខា ឬ ផ្តិតស្រាមដៃជាមួយយើង។

| អ្នកឆ្លើយ | ក្រឡាបញ្ជី | ព្រះរាជអាជ្ញារង |
|---|---|---|

# ឧបសម្ព័ន្ធទី២

# ទម្រង់នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥
លេខ ៤៥៩៦ អ.យ.ទ

**ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ**

**យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

- បានឃើញ របាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់[1] អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

យល់ឃើញថា មានតម្រុយសន្មតបានថា៖

១- នាមត្រកូល-នាមខ្លួន ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ "ស" ម្តាយឈ្មោះ "រ" ទោសពីមុន "គ្មាន" ជា-នីតិជន។

២- ឈ្មោះ ហៅ ភេទប្រុស ប្រពន្ធឈ្មោះ (គេចខ្លួន)

៣- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៤- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៥- ឈ្មោះ ភេទប្រុស (គេចខ្លួន)

៦- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបររើសអេតចាយ នៅលីវ ឪពុកឈ្មោះ "រ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

៧- ឈ្មោះ ភេទស្រី ប្តីឈ្មោះ ហៅ (គេចខ្លួន)

**បានប្រព្រឹត្តអំពើដូចតទៅ[2] ÷**

កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣និង១៥នាទី ទាបភ្លឺ ជនសង្ស័យឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ . . . . . ហៅ ឈ្មោះ ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY ១00 Plus ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក

---

[1] លេខសំណុំរឿងរបស់នគរបាលយុត្តិធម៌

[2] សេចក្តីសង្ខេបអង្គហេតុ

ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ហើយជនសង្ស័យឈ្មោះ បានធ្វើសកម្មភាពយកទួរ៉ឺវីសឆ្កឹះសោទ្វារខាងមុខ ចំណែកជនសង្ស័យឈ្មោះ បានឆ្កឹះសោទ្វារខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ដុល្លារចំនួន៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនសង្ស័យបានគេចខ្លួនទៅផ្ទះរបស់ជនសង្ស័យឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ

បានទទួលប្រាក់ចំនួន ១លានរៀល។ ក្រោយមកជនសង្ស័យឈ្មោះ បានយកប្រាក់ចំនួន៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនសង្ស័យឈ្មោះ ។ ចំណែកជនសង្ស័យឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន ១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវ ហើយឃាត់ខ្លួនជនសង្ស័យពីរនាក់មានឈ្មោះ និងឈ្មោះ

ព្រមទាំងដកហូតវត្ថុតាងដូចមានក្នុងកំណត់ហេតុ ដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

អំពើរបស់ឈ្មោះ ឈ្មោះ ហៅចយ ឈ្មោះ ឈ្មោះ និងឈ្មោះ ជាបទល្មើសលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

អំពើរបស់ឈ្មោះ ជាបទល្មើស ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

បានឃើញ មាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**ហេតុដូច្នេះសម្រេច**</u>

- បើកការស៊ើបសួរលើអង្គហេតុខាងលើ និង

☑ ដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើឈ្មោះ[៣]

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

---

[៣] ឈ្មោះជនត្រូវចោទ

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ២៩-៣៥៣-៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៧- ភេទស្រី

ពីបទ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE₀ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៩៩-៤០០ នៃក្រមព្រហ្មទណ្ឌ។

☐ ដាក់អោយស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ[៦]៖ ..........................................។

☑ ដាក់អោយស្ថិតនៅក្រោមការឃុំខ្លួនបណ្ដោះអាសន្ន[៧]៖

១- ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> (ឃាត់ខ្លួន)

២- ៖ ហៅ ភេទប្រុស (គេចខ្លួន)

៣- ភេទប្រុស (គេចខ្លួន)

៤- ភេទប្រុស (គេចខ្លួន)

៥- ភេទប្រុស (គេចខ្លួន)

ពីបទ៖ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៦- ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> (ឃាត់ខ្លួន)

ពីបទ៖ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា

៧- ភេទស្រី ពីបទ ទទួលផលចោរកម្ម

- ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី ៖
  - បញ្ឈប់បទល្មើស ឬ បង្ការបទល្មើសកុំឲ្យកើតជាថ្មី
  - រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ
  - ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី
  - រារាំងការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងបក្ខពួក។

រាជធានីភ្នំពេញ ថ្ងៃទី <u>១៤</u> ខែតុលា ឆ្នាំ២០១៥

ជ. ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

---

[៦] ភាតព្វកិច្ចណាមួយដែលបានចែងនៅក្នុងមាត្រា២២៣

[៧] មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្នដែលបានចែងនៅក្នុងមាត្រា២០៥

# ឧបសម្ព័ន្ធទី៣

# ទម្រង់នៃដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន

/៖

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

++++++

អយ្យការអម

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩

ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥

# ដីកាសន្និដ្ឋានសុំឲ្យឃុំខ្លួនបណ្ដោះអាសន្ន

**យើង** ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៦៥៤៩. អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ ដែលបើកការស៊ើបសួរពីបទ៖ សមគំនិត និងលួចមានស្ថានទម្ងន់ទោសដោយការប្រព្រឹត្តហិង្សា។
- បានឃើញដីកាបញ្ជូនឲ្យឆ្លើយរបស់ចៅក្រមស៊ើបសួរចុះថ្ងៃទី ........ ខែ........... ឆ្នាំ..............
- បានឃើញមាត្រា ២០៣, ២០៥, និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**ដោយហេតុថា ការឃុំខ្លួនបណ្ដោះអាសន្នជាមូលហេតុតែមួយគត់ដើម្បី**

□ បញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី

□ រារាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឲ្យមានការ ត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត

□ រក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

□ ធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

□ ការពារសន្តិសុខឲ្យជនត្រូវចោទ

□ ធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស

**យល់ឃើញថា ÷**

ការឃុំខ្លួនបណ្ដោះអាសន្នជាមធ្យោបាយសំរាប់បញ្ចប់ភាពចលាចលធ្ងន់ធ្ងរ និងយូរអង្វែងចំពោះ សណ្ដាប់ធ្នាប់សាធារណៈ ដោយមូលហេតុ៖

□ ភាពធ្ងន់ធ្ងរនៃបទល្មើស

□ កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស

□ ទំហំនៃព្យសនកម្មដែលបង្កឡើងដោយបទល្មើស

**ម្ដីងសុំឲ្យចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនបណ្ដោះអាសន្នលើ**

១- នាមត្រកូល-នាមខ្លួន ភេទប្រុស អាយុ១៤ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិស្វាយតាអុក សង្កាត់ភ្លៅស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរ រើសអេតចាយ នៅលីវ ឪពុកឈ្មោះ -ស- ម្ដាយឈ្មោះ -រ- ទោសពីមុន -គ្មាន- ជា-នីតិជន។

២- នាមត្រកូល-នាមខ្លួន ហៅ ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ជនជាតិខ្មែរ កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃភូមិតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរើសអេតចាយ នៅលីវ ឪពុកឈ្មោះ "វ" ម្តាយឈ្មោះ "ស" ទោសពីមុន "គ្មាន" ជា-នីតិជន។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែតុលា ឆ្នាំ២០១៥

ជ.ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

# ឧបសម្ព័ន្ធទី៤

# ដីកាសន្និដ្ឋានស្ថាពរ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌលេខ ៨០៣៩
ចុះថ្ងៃទី ១៣ ខែតុលា ឆ្នាំ ២០១៥
លេខ ៖ ៦៣ អ.យ.ទ

# ដីកាសន្និដ្ឋានស្ថាពរ

យើង ព្រះរាជអាជ្ញារង នៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

- បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ៨០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ សំណុំរឿងស៊ើបសួរលេខ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យលេខ២១១៦៩ ត.ព្រ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ ។

## ក្រោយពីបានពិនិត្យឯកសារខាងលើ

ឃើញថា

១. គោត្តនាម-នាម ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់ភ្នំពេញ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរើសអេតចាយ នៅ លីវ ឪពុកឈ្មោះ ស្លាប់-ម្តាយឈ្មោះ រស់-ទោសពីមុន គ្មាន-ជា<u>អនីតិជន</u>។

២.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជនជាតិខ្មែរ (ឃាត់ខ្លួន) កើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ (រ) កូនគ្មាន ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ជានីតិជន ទោសពីមុនគ្មាន។

៣.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៤.ឈ្មោះ ភេទប្រុស(គេចខ្លួន)

៥.ឈ្មោះ ភេទប្រុស(គេចខ្លួន)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៦.គោត្តនាម-នាម ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជនជាតិខ្មែរ(ឃាត់ខ្លួន) កើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង សាសនាព្រះពុទ្ធ ទីលំនៅសព្វថ្ងៃ ភូមិស្វាយតាអុក សង្កាត់ភាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មុខរបរើសអេតចាយ នៅ លីវ ឪពុកឈ្មោះ រស់-ម្តាយឈ្មោះ ស្លាប់-ទោសពីមុន-គ្មាន-ជាអនីតិជន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៧. ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ មានទីលំនៅបច្ចុប្បន្ន ភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ប្តីឈ្មោះ ហៅ (រ) កូនគ្មាន ជានីតិជន ទោសពីមុនគ្មាន។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

**ឃើញថា**

កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ៣ម១៥នាទី ទាបភ្លឺជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ, ឈ្មោះ ហៅ , ឈ្មោះ ឈ្មោះ និង ឈ្មោះ បានជិះម៉ូតូម៉ាក CITY 100PLUS ពណ៌ក្រហម គ្មានស្លាកលេខ លេខម៉ាស៊ីន ០១៧៤៤៦ ដោយមានសណ្តោងរ៉ឺម៉ក ដែលជាកម្មសិទ្ធិរបស់ឈ្មោះ ... ... ភេទប្រុស អាយុ១៥ឆ្នាំ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ មានជនត្រូវចោទឈ្មោះ បានធ្វើសកម្មភាពយកឌូឡើរ៍សផ្ដិះសោរទ្វារខាងមុខ ចំណែកជនត្រូវចោទឈ្មោះ បានផ្ដិះសោរទ្វាខាងក្នុង រួចនាំគ្នាចូលក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួនមួយ ដែលក្នុងនោះមានប្រាក់ចំនួនប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និងឯកសារប្លង់ដី ព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួនមួយ។ បន្ទាប់មកជនត្រូវចោទបានគេចខ្លួនទៅផ្ទះរបស់ជនត្រូវចោទឈ្មោះ ហើយយកប្រាក់ទាំងនោះចែកជាចំណែក ដោយឈ្មោះ បានទទួលប្រាក់ចំនួន១លានរៀល។ ក្រោយមកជនត្រូវចោទឈ្មោះ បានយកប្រាក់ចំនួន៤ពាន់ដុល្លារអាមេរិក ផ្ញើទុកនៅនឹងឈ្មោះ ត្រូវជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ។ ចំណែកជនត្រូវចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការ

ស្រាវជ្រាវ ហើយឃាត់ខ្លួនជនត្រូវចោទពីរនាក់មានឈ្មោះ និង ឈ្មោះ ព្រមទាំងដកហូតវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធីច្បាប់។

បានឃើញរបាយការណ៍សំយោគលេខ ២០៩/១៥ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ជនត្រូវចោទឈ្មោះ (ឃាត់ខ្លួន) និងបក្ខពួកឈ្មោះ ,ឈ្មោះ , ឈ្មោះ និង ឈ្មោះ (គេចខ្លួន) ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស កាលពីវេលាម៉ោង ០៣ម១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនស៊ីហ្គាទេសចរណ៍ និង ពាណិជ្ជ មានទីតាំងផ្ទះលេខ ៨១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន។ ចំណែកជនត្រូវចោទឈ្មោះ (ឃាត់ ខ្លួន) ពិជាបានសមគំនិត ផ្តល់ជាមធ្យោបាយធ្វើសកម្មភាព និង ទទួលផលចោរកម្ម ក្នុងករណីនេះប្រាកដមែន រីឯឈ្មោះ (គេចខ្លួន) ដែលជាប្រពន្ធរបស់ជនត្រូវចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្ម ក្នុងករណីនេះផងដែរ។

បានឃើញចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ បានឆ្លើយនៅសមត្ថកិច្ចថា ៖កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុនរបស់ខ្លួន មានទីតាំងផ្ទះលេខ ៨១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅសំរាកនៅផ្ទះ។ លុះដល់ម៉ោងប្រហែល ០៨ម០០នាទី ទៀបភ្លឺចូលថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពុងសំរាក ក៏មានសមត្ថកិច្ចទូរស័ព្ទមកប្រាប់ខ្លួនថា ក្រុមហ៊ុនរបស់ខ្លួនត្រូវបានចោរគាស់ទ្វារ ពេលនោះ ខ្លួនក៏បានមកមើល ទើបដឹងថា បាត់ទូដែកចំនួន០១ ហើយក្នុងទូដែកនោះមានប្រាក់ចំនួន ៥ម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន ២លានរៀល ឯកសារប្លង់ដីមួយចំនួន សៀវភៅធនាគារចំនួន០៣ក្បាល និង បាត់ម៉ាស៊ីនស្កេនចំនួន០១គ្រឿងផងដែរ។

បានឃើញចម្លើយរបស់សាក្សីឈ្មោះ /បានឆ្លើយនៅសមត្ថកិច្ចថា៖ កាលពីថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ខ្លួនបានចេញពីក្រុមហ៊ុន ត្រលប់ទៅផ្ទះសំរាក ដោយខ្លួនបានចាក់សោរទ្វាក្រុមហ៊ុនត្រឹមត្រូវ។ លុះទៀបភ្លឺថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្លួនបានទូរស័ព្ទមកប្រាប់ខ្លួនថា នៅក្រុមហ៊ុនមានចោរចូលគាស់ទ្វា ពេលនោះខ្លួនក៏ប្រញាប់មកក្រុមហ៊ុន រួចទើបដឹងថាចោរលួចយកទូរដែក០១ នៅក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៨ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល ០៣ម ១៥នាទី ខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃ ដោយលួចបានទូរដែកប្រាកដមែន។ មុនដំបូងឈ្មោះ ( ) បានយកម៉ូតូ០១គ្រឿងម៉ាកសេ១០០ក្បរជ្រើសពណ៌ក្រហម គ្មានស្លាកលេខ ពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉ក ដឹករូបខ្លួន និង បក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ។ ពេលពួកខ្លួនធ្វើដំណើរមកដល់ម្តុំទួលស្វាយព្រៃ ក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោរនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយខ្លួនក៏បានយកទុលឡឺវីសមកផ្តិះសោរស្វឡិចទ្វាខាងមុខ ចំណែកឈ្មោះ ផ្តិះសោរទ្វាខាងក្នុង រួចនាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយ និងលួចយកបានទូរដែក០១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉ក ទៅផ្ទះរបស់ឈ្មោះ

ដើម្បីគាស់ បានឃើញលុយដុល្លារជាច្រើន និង ឯកសារផ្សេងទៀត ហើយចែកលុយគ្នា ដោយខ្លួនទទួលបានប្រាំមួយពាន់ដុល្លារ រីឯឯកសារទាំងនោះត្រូវបានដុតចោល។ បន្ទាប់មកខ្លួនបានយកលុយចំនួនបួនពាន់

ដុល្លារទៅធ្វើរនិងឈ្មោះ ហើយសល់បិន្ទានខ្លួនទៅចាយវាយនិងចែកអ្នកជិតខាងនៅស្វាយរៀង។ លុះដល់ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី រសៀល ពេលខ្លួនកំពុងអង្គុយលេងជាមួយឈ្មោះ និង ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួន។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ បានឆ្លើយនៅសមត្ថកិច្ច និងនៅអយ្យការ ប្រហាក់ប្រហែលទៅនឹងចម្លើយនៅចៅក្រមស៊ើបសួរថា៖ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០១៥ ខ្លួនពិតជាបានអោយម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែក ប្រាកដមែន។ មុនដំបូងនៅល្ងាចថ្ងៃទី ០៨ ខែតុលា ឆ្នាំ២០១៥ ឈ្មោះ បានទូរសព្ទមកខ្លួនអោយទៅយកគេនៅម៉ុប្បារអំពៅ ពេលនោះខ្លួនក៏បានជិះម៉ូតូម៉ាក ១០០ កូរ៉េឆ្លើស ពណ៌ក្រហម គ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្លួនជិះ រួចខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ។ មូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្លួន គឺម៉ូតូរបស់ខ្លួនមានប្រដាប់សណ្តោងរ៉ឺម៉កស្រាប់។ លុះព្រឹកឡើងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល៧ម០០នាទី ឈ្មោះ បានទូរស័ព្ទមកខ្លួនអោយយកមកម៉ូតូ និង បានឲ្យលុយមកខ្លួនចំនួនមួយលានរៀល។ រហូតដល់ថ្ងៃទី ១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣ម០០នាទី ខ្លួនបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និង ឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់មានសមត្ថកិច្ចមកឃាត់រូបខ្លួន និង ឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលខណ្ឌការមនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់។

បានឃើញ ចម្លើយរបស់ជនត្រូវចោទឈ្មោះ ភេទប្រុស បានឆ្លើយនៅចៅក្រមស៊ើបសួរថា៖ ខ្លួនពិតជាបានចូលរួមប្រព្រឹត្តអំពើលួចគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ ក្នុងនោះមានឈ្មោះ , ឈ្មោះ , ឈ្មោះ , ឈ្មោះ ហៅ ។ ពេលនោះពួកខ្លួនលួចបាន ទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិកគត់) ហើយក៏បានចែកគ្នា ដោយរូបខ្លួនបានចំណែកចំនួន ១០,០០០$ (មួយម៉ឺនដុល្លារអាមេរិកគត់) លុយសល់ពីនោះ ទុកឲ្យបក្ខពួក៤នាក់ទៀតចែកគ្នា។ ចំណែកទូរដែកនោះ បានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បារអំពៅ។

- ដីកាបង្គាប់ឲ្យចូលខ្លួនលេខ ១៨៤៨៦ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យនាំខ្លួនលេខ ៨០៦ ចុះថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៥១៦៣ ត.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ៣៥២៦ ក.ព្រ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៤១២៤ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ ក.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្នលេខ ៤១២៣ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៩ ត.ព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបញ្ជូនឲ្យឆ្លើយលេខ ២០៩១២ តព្រ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១៥ របសចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាបង្គាប់ឲ្យចាប់ខ្លួនលេខ ៨១៣ តព្រ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ។

- ដីកាចាត់ឲ្យស៊ើបសួរជំនួសលេខ ១៨៤៨៩ តព្រ ចុះថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ លើឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស។

- របាយការណ៍របស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ តាមការចុះស្រាវជ្រាវរកឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ពុំមានស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤នោះទេ។

- លិខិតជូនដំណឹង ឬជូនព័ត៌មានដល់តំណាងអយ្យការលេខ ២០៧៣៧ ត.ព្រ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ ។

- ឯកសារមួយចំនួនទៀតដែលពាក់ព័ន្ធសំណុំរឿង ។

## <u>យល់ឃើញថា</u>

- តាមចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សាក្សី និងចម្លើយសារភាពរបស់ជនត្រូវចោទ ហេនភាពស៊ីសង្វាក់ទៅនឹងភស្តុតាងអាចបង្ហាញឲ្យឃើញថា ៖ ជនត្រូវចោទឈ្មោះ ភេទប្រុស ងាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> និង ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ពិតជាបានប្រព្រឹត្តអំពើឆ្លើះសោរទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ដើម្បីលួចយកប្រាក់របស់ជនរងគ្រោះឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពិតប្រាកដមែន ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ, ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u>, ឈ្មោះ ភេទប្រុស (គេចខ្លួន), ឈ្មោះ ភេទប្រុស (គេចខ្លួន) និង ឈ្មោះ ភេទប្រុស (គេចខ្លួន) គឺអំពើដកហូតទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត តាមមធ្យោបាយឆ្លើះសោទ្វារក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ ដើម្បីមកធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសលួចមានស្ថានទម្ងន់ទោស និងបញ្ញត្តិឲ្យផ្ដន្ទាទោសតាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> គឺជាអំពើសំរបសំរួលដើម្បីសម្រេចបាននូវសកម្មភាពក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិតតាមមធ្យោបាយឆ្លើះសោទ្វារក្រុមហ៊ុន

ស៊ីហ្គាទេសចរណ៍ដើម្បីយកប្រាក់ធ្វើជាកម្មសិទ្ធរបស់ខ្លួន ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយប្រើអំពើហិង្សា និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

- អំពើរបស់ឈ្មោះ ភេទប្រុស អាយុ២២ឆ្នាំ គឺជាអ្នកទទួលផលក្នុងអំពើលួចទ្រព្យសម្បត្តិរបស់ជនរងគ្រោះដោយចេតនាទុច្ចរិត ដែលធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ ហើយធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ ព្រមទាំងរបៀបរៀបរយល្អរបស់សង្គម ដែលច្បាប់បញ្ញត្តិថាជាបទល្មើសទទួលផលចោរកម្ម និងបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

- ឈ្មោះ ភេទប្រុស អាយុ២៧ ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជានីតិជនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និង ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជា អនីតិជន ប៉ុន្តែមានលក្ខណៈសម្បត្តិយល់ដឹងធនល្មមក្នុងការទទួលខុសត្រូវចំពោះមុខច្បាប់ នូវអំពើដែលខ្លួនបានប្រព្រឹត្ត។

- មានភស្តុតាងគ្រប់គ្រាន់សម្រាប់ដាក់បន្ទុកលើឈ្មោះ និង ឈ្មោះ ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា, ឈ្មោះ ភេទប្រុស ពីបទៈសមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងឈ្មោះ ភេទស្រី ពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ។

- តាមលទ្ធផលស្រាវជ្រាវរបស់នគរបាលប៉ុស្តិ៍ទួលស្វាយព្រៃទី១ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៥ រកពុំឃើញឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ជាប់ចោទពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ស្ថិតិស្នាក់នៅនិងសាវតាជាតិនៅក្នុងមូលដ្ឋានមណ្ឌលទី៤ ទេ។

- យោងតាមមាត្រា ២៤៧ ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧១ និងមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ គប្បីចៅក្រមលើកលែងចោទប្រកាន់លើឈ្មោះ ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស ដោយហេតុជនត្រូវចោទនេះពុំសាវតាជាតិពិតប្រាកដ។

## ហេតុដូច្នេះ

ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច ៖

☑ បញ្ជូនជនត្រូវចោទឈ្មោះ

១. ...... ភេទប្រុស អាយុ២៧ឆ្នាំ (ឃាត់ខ្លួន)

២. ...... ភេទប្រុស អាយុ១៤ឆ្នាំ(ឃាត់ខ្លួន) ទៅជំនុំជម្រះ។

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោស តាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣. ភេទប្រុស អាយុ១៥ឆ្នាំ (ឃាត់ខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩, មាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤. ភេទស្រី អាយុ២២ឆ្នាំ (គេចខ្លួន) ទៅជំនុំជម្រះ

ពីបទ ៖ទទួលផលចោរកម្ម ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩ និង មាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ ។

☑ លើកលែងចោទប្រកាន់

- ឈ្មោះ ភេទប្រុស, ឈ្មោះ ភេទប្រុស និង ឈ្មោះ ភេទប្រុស

ពីបទ ៖លួចមានស្ថានទម្ងន់ទោសដោយសារប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តិនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ មានទីតាំងផ្ទះលេខ ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣ និង មាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០១៦

ព្រះរាជអាជ្ញា

**ព្រះរាជអាជ្ញារង**

# ឧបសម្ព័ន្ធទី៥
# ដីការសម្រេចរក្សាជនជាប់ចោទក្នុង
# ឃុំបណ្ដោះអាសន្ន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខ 359.....(ព)ដឃដ

20.01.16

៧៤/១

**ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្ដោះអាសន្ន**

យើង : ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ អមដោយលោក ជាក្រឡាបញ្ជី ។

-បានឃើញមាត្រា២៤៩ មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២៥៥៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថានពរលេខ: ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-ឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភូលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (ស) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទ: សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២៨៣៤ តព្រ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

**យល់ឃើញថា**

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតមានជាថ្មី ដើម្បីរក្សាជនជាប់ចោទទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខឲ្យជនជាប់ចោទដើម្បីរក្សាសណ្ដាប់ធ្នាប់កុំឲ្យមានការច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស ។

**ហេតុដូច្នេះសម្រេច**

-បង្គាប់មកលោកប្រធានពន្ធនាគារ (ម២) ឲ្យរក្សាការឃុំខ្លួនឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> រហូតដល់បង្ហាញខ្លួននៅមុខសាលាដំបូងរាជធានីភ្នំពេញ។

បានទទួលដំណឹង

រាជធានីភ្នំពេញថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

ជ.ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

ព្រះរាជអាជ្ញារង

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

# ឧបសម្ព័ន្ធទី៦
# ដីកាលើកលែងចោទប្រកាន់

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ ( ៣ )

លេខ 270 ដជ

## ដីកាលើកលែងចោទប្រកាន់

យើង ចៅក្រមស៊ើបសួរ សាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញមាត្រា ២៤៧ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញដីកាសន្និដ្ឋានឲ្យស៊ើបសួរលេខ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការ អមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងស៊ើបសួរលេខ ២៦០៥ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥ របស់សាលាដំបូងរាជធានីភ្នំពេញ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

ក្រោយពីបានស៊ើបសួរ និងពិនិត្យសំណុំរឿងចប់សព្វគ្រប់

### សំអាងហេតុ

១.ជនត្រូវចោទឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

២.តាមដីកាសន្និដ្ឋានស្ថាពរលេខ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្ដឹងសុំឲ្យចៅក្រមស៊ើបសួរលើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) ដែលត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។ គប្បីចៅក្រមស៊ើបសួរចេញដីកាដំណោះស្រាយ លើកលែងចោទប្រកាន់លើឈ្មោះ ភេទប្រុស ,ឈ្មោះ ភេទប្រុស និងឈ្មោះ ភេទប្រុស (គ្មានអត្តសញ្ញាណ) តាមមាត្រា២៤៧ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៤៧ ក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

លើកលែងចោទប្រកាន់លើឈ្មោះ      ភេទប្រុស ,ឈ្មោះ      ភេទប្រុស និងឈ្មោះ      ភេទប្រុស (គ្មានអត្តសញ្ញាណ) ពីបទៈលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

លេខ ៦៨ អ.យ.ទ

បានទទួលដំណឹង

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០១៦

ជ. ព្រះរាជអាជ្ញា

ព្រះរាជអាជ្ញារង

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

# ឧបសម្ព័ន្ធទី៧

# ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

សាលាដំបូងរាជធានីភ្នំពេញ

មន្ទីរស៊ើបសួរ (៣)

លេខ ៦១ ដ.ជ

យើង ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ

អមដោយលោក ជាក្រឡាបញ្ជី ។

បានឃើញ មាត្រា ២៤៧ និងមាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខៈ ២៥៩៤ អ.យ.ទ ចុះថ្ងៃទី១៤ ខែតុលា ឆ្នាំ២០១៥ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញ ដីកាសម្រេចរក្សាជនជាប់ចោទក្នុងឃុំបណ្តោះអាសន្នលេខ៦៩៦,៦៩១,៦៩០(ក)ដយដ ចុះថ្ងៃទី....១៦.... ខែមករា ឆ្នាំ២០១៦។

ក្រោយពីបានពិនិត្យស៊ើបសួរចប់សព្វគ្រប់ហើយយល់ឃើញថា មានពិរុទ្ធភាពគ្រប់គ្រាន់លើ :

១.ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់ភូមិវាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) នៅលើវ ជានីតិជន។

២.ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតភូមិស្លែង សង្កាត់ច្បារអំពៅ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ មានទីលំនៅបច្ចុប្បន្នភូមិស្លែង សង្កាត់ច្បារអំពៅទី២ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣.ឈ្មោះ ហៅ ភេទប្រុស <u>អាយុ១៥ឆ្នាំ</u> ជាតិខ្មែរ មុខរបរ រើសអេតចាយ ទីកន្លែងកំណើតនៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិស្វាយតាអុក សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្តាយឈ្មោះ (ស) នៅលើវ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្តន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាលទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា២៩,មាត្រា៣៥៣ និងមាត្រា៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤.ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្ននៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស) ម្ដាយឈ្មោះ (រ) ប្ដីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន។

ប្រវត្តិនៃការផ្ដន្ទាទោសតាមផ្លូវតុលាការៈ គ្មាន។

ជាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គាល ទេសចរណ៍ និងពាណិជ្ជ ទីតាំងផ្ទះលេខ៤១BE0 ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ តាមមាត្រា៣៩៩ និងមាត្រា៤០០ នៃក្រមព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

បញ្ជូនជនត្រូវចោទឈ្មោះ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ,ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ,ឈ្មោះ ភេទប្រុស អាយុ១៥ឆ្នាំ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ខាងលើនេះ និងសំណុំរឿងព្រហ្មទណ្ឌលេខៈ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ ព្រមទាំងវត្ថុតាង និងបញ្ជីរាយនាមជនដែលទាក់ទិនក្នុងរឿងនេះ ទៅប្រធានសាលាដំបូងរាជធានីភ្នំពេញដើម្បីកំណត់ពេលសវនាការជំនុំជម្រះ។

បានទទួលដំណឹង

ាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០

ជ. ព្រះរាជអាជ្ញា

ក្រឡាបញ្ជី

រាជធានីភ្នំពេញ ថ្ងៃទី ១៦...ខែមករា ឆ្នាំ២០១៦

ចៅក្រមស៊ើបសួរ

ព្រះរាជអាជ្ញារង

# ឧបសម្ព័ន្ធទី៨
# សាលក្រមរបស់សាលាដំបូងរាជធានី
# ភ្នំពេញ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**នាមនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ
លេខ :៤០៣៩
ចុះថ្ងៃទី១៣/១០/២០១៥
ជំនុំជំរះលេខ: ១៩៧
ចុះថ្ងៃទី២២/០១/២០១៦
សាលក្រមព្រហ្មទណ្ឌ
លេខ: ១៤១ ក្រ៨ "ជ"
ចុះថ្ងៃទី២២/០៤/២០១៦

បានបើកសវនាការជាសាធារណៈនៅសាលាដំបូងរាជធានីភ្នំពេញនាថ្ងៃទី ០៧ ខែមេសា ឆ្នាំ២០១៦ នៅវេលាម៉ោង ០៨.៣០នាទី ព្រឹកដែលមានសមាសភាពដូចខាងក្រោម :

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក ប្រធានក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា
លោក ចៅក្រុមប្រឹក្សា

**តំណាងអយ្យការ**

លោក ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជំរះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៤០៣៩ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ មានជនជាប់ចោទ:

១/ឈ្មោះ ភេទប្រុស អាយុ១៤ឆ្នាំ ជនជាតិខ្មែរ មុខរបរដើររើសអេតចាយ ទីកន្លែងកំណើតសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក សង្កាត់វាស្សូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ)នៅលីវ ជាអនីតិជន ។

-ឃាត់ខ្លួននៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៩ ត.ព ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១៥។

២/ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិស្លែង សង្កាត់ច្បារអំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ (ស) ម្តាយឈ្មោះ (រ) ប្រពន្ធឈ្មោះ (រ) ជានីតិជន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ៣៥២៦ តព ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៥ ។

ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៣/ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ មុខរបរដើររើសអេតចាយទីកន្លែងកំណើតស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅបច្ចុប្បន្នភូមិស្វាយតាអុក

សង្កាត់វាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ឪពុកឈ្មោះ (រ) ម្ដាយឈ្មោះ (រ) ជាអនីតិជន ទោសពីមុនគ្មាន ។

-ឃាត់ខ្លួនកាលពីថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

-និងឃុំខ្លួនតាមដីកាលេខ២៨៣៤ តព្រ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥។

ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៤/ឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ទីលំនៅសព្វថ្ងៃភូមិគ្រួស ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង ឪពុកឈ្មោះ (ស)ម្ដាយឈ្មោះ (រ)ប្ដីឈ្មោះ ទោសពីមុនគ្មាន ជានីតិជន(ក្រៅឃុំ) ។

ដោយមានកញ្ញា ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្ដន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរជាប្រធានក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍និងពាណិជ្ជ ទីលំនៅកំណើតឃុំកំពង់សៀម ស្រុកកំពង់សៀម ខេត្តកំពង់ចាម ទីលំនៅសព្វថ្ងៃផ្ទះលេខ២៧៩BE០ ផ្លូវ១៨២ ភូមិ៨ សង្កាត់ទឹកល្អក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-បានឃើញ របាយការណ៍សំយោគលេខ ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ៦៣ អ.យ.ទ ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០១៦ របស់ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជំរះលេខ ២០៩ ជ.ជ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ ។

**<u>អង្គហេតុដែលត្រូវបានចោទប្រកាន់និងបញ្ជូនមកជំនុំជម្រះ</u>**

កាលពី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីទាបភ្លឺជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ , ឈ្មោះ , ឈ្មោះ និងឈ្មោះ បានជិះម៉ូតូម៉ាក CITY 100 PLUS ពណ៌ក្រហមគ្មានស្លាកលេខ លេខម៉ាស៊ីន០១៧៤៤៦ ដោយមាន សណ្ដោងរ៉ឺម៉កដែលជាកម្មសិទ្ធិរបស់ឈ្មោះ មកឈប់នៅខាងមុខក្រុមហ៊ុនស៊ិនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន មានជនជាប់ចោទឈ្មោះ បានធ្វើសកម្មភាពយកទូឡឺវីសឆ្កឹះសោទ្វាខាងមុខចំណែកជនជាប់ចោទឈ្មោះ បានឆ្កឹះសោទ្វាខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនលួចយកទូរដែកចំនួន១ ដែលក្នុងនេះមានប្រាក់ចំនួន

ប្រាំម៉ឺនដុល្លារអាមេរិក ប្រាក់រៀលចំនួន២លានរៀល និង ឯកសារប្លង់ដីព្រមទាំងសៀវភៅធនាគារ និងលួចយកម៉ាស៊ីនស្កេនចំនួន១ បន្ទាប់មកជនជាប់ចោទបានគេចខ្លួនទៅផ្ទះរបស់ឈ្មោះ ហើយបានយកប្រាក់ទាំងនេះចែកជាចំណែក ដោយឈ្មោះ ទទួលបានប្រាក់ចំនួន១លានរៀល បន្ទាប់មកជនជាប់ចោទឈ្មោះ បានយកប្រាក់ចំនួន៤,០០០$ផ្ញើទុកនៅនឹងឈ្មោះ ដែលត្រូវជាប្រពន្ធរបស់ជនជាប់ចោទរបស់ឈ្មោះ ។ ចំណែកជនជាប់ចោទឈ្មោះ បានឲ្យប្រាក់ទៅប្រពន្ធចំនួន១ម៉ឺនដុល្លារអាមេរិក រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ សមត្ថកិច្ចបានធ្វើការស្រាវជ្រាវហើយឃាត់ខ្លួនជនជាប់ចោទបានចំនួន២នាក់គឺឈ្មោះ . និងឈ្មោះ ព្រមទាំងដកហូតបានវត្ថុតាងដើម្បីកសាងសំណុំរឿងចាត់ការតាមនីតិវិធី ។

<u>នាពេលសវនាការ</u>

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទី ខ្ញុំពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយគ្រឿងម៉ាកសេ១០០ក្បរ៉េផ្លើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតកន្ទុយរ៉ឺម៉កបានដឹកប្អូនខ្ញុំនិងបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលពួកខ្ញុំធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្ញុំក៏បានឈប់ម៉ូតូហើយខ្ញុំក៏បានយកទួឡឺវីសមកឆ្កឹះសោស្ទូឡិចទ្វារខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វារខាងក្នុងរួចបាននាំគ្នាចូលទៅក្នុងក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើ ហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសារផ្សេងទៀត រួចហើយបានចែកលុយគ្នាដោយខ្ញុំទទួលបានប្រាំពាន់ដុល្លារអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្ញុំបានយកលុយចំនួន៤ពាន់ដុល្លារអាមេរិក ទៅផ្ញើនិងឈ្មោះ . នៅសល់ប៉ុន្មានពួកខ្ញុំបានយកទៅចាយវាយនិងចែកអ្នកជិតខាង នៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទីរសៀលខ្ញុំកំពង់អង្គុយលេង ជាមួយឈ្មោះ . និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកដល់ ហើយឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ខ្ញុំពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះរបស់គេលួចទូរដែកប្រាកដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្ញុំឲ្យយកទៅគេនៅម្តុំផ្សារអំពៅ ពេលនោះខ្ញុំក៏បានជិះម៉ូតូម៉ាកសង់សេ១០០ ក្បរ៉េផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានខ្ចីម៉ូតូរបស់ខ្ញុំជិះរួចខ្ញុំក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញមូលហេតុដែលឈ្មោះ ខ្ចីម៉ូតូរបស់ខ្ញុំគឺម៉ូតូរបស់ខ្ញុំមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ឲ្យខ្ញុំមកយកម៉ូតូ និងបានឲ្យលុយមកខ្ញុំចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល១៣,០០នាទី ខ្ញុំបានជិះម៉ូតូមកអង្គុយលេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនខ្ញុំ និងឈ្មោះ នាំមកកាន់អធិការដ្ឋាននគរបាលតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

-ជនជាប់ចោទឈ្មោះ ឆ្លើយនៅពេលសវនាការថាៈ ខ្ញុំពិតជាបានចូលរួមគាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ ,ឈ្មោះ ,ឈ្មោះ ហៅ ។ ពេលនោះពួកខ្ញុំលួចបានទូដែក១ យកទៅបើកនៅផ្ទះរបស់ខ្ញុំ ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្ញុំបានចំនួន១០,០០០$ លុះសល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបានបោះចោល ជាមួយឯកសារនៅក្បែរវត្តច្បាអំពៅ ។

-ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ នៅពេលសវនាការថាៈ កាលពី ថ្ងៃទី០៨ខែតុលា ឆ្នាំ២០១៥ ខ្ញុំបានចេញពីក្រុមហ៊ុនរបស់ខ្ញុំមានទីតាំងផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេល ខ្ញុំកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទ័ប្រាប់ខ្ញុំថា ក្រុមហ៊ុនរបស់ខ្ញុំត្រូវមានចោរលួចគាស់ទ្វា ពេលនោះខ្ញុំក៏បាននមកមើល ទើបទឹងថាបាត់ទូរដែកចំនួន១ ហើយក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវ ភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ នៅក្នុងរឿងនេះខ្ញុំសុំទាមទារប្រាក់ដែលបានបាត់បង់ទៅសរុបចំនួន ៥០,០០០$ លុយខ្មែរចំនួន២,០០០,០០០រៀល ព្រមទាំងឯកសារផ្សេងៗទៀត ។

-ក្រឡាបញ្ជីអានចម្លើយសាក្សីឈ្មោះ នៅពេលសវនាថា : កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ ខ្ញុំបាន ចេញពីក្រុមហ៊ុនត្រលប់ទៅផ្ទះសម្រាក ហើយខ្ញុំបានចាក់សោរទ្វាត្រឹមត្រូវលុះទាមភ្លឺថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ប្រធានក្រុមហ៊ុនរបស់ខ្ញុំបានទូរសព្ទ័មកប្រាប់ខ្ញុំថា នៅក្រុមហ៊ុនមានចោរ ចូលគាស់ទ្វា ពេលនោះខ្ញុំក៏ប្រញាប់មកក្រុមហ៊ុន ទើបដឹងថាចោរបានលួចយកទូរដែក១នៅ ក្នុងបន្ទប់របស់ប្រធានក្រុមហ៊ុន ។

-តំណាងយ្យការធ្វើសេចក្តីសន្និដ្ឋានថាៈ ក្រោយពីបានសួរដេញដោលចប់សព្វគ្រប់ឃើញថា ជនជាប់ឈ្មោះ ,ឈ្មោះ និងឈ្មោះ បានឆ្លើយសារភាពថាពួកខ្លួនពិតជាបានលួចគាស់ទ្វាក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជដោយលួចបានទូរដែកចំនួន១ ហើយនៅក្នុងទូរដែកនេះមានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ រួចហើយពួកខ្លួនក៏បានយកលុយទៅចែកគ្នាអស់ ចំណែកឯកសារផ្សេងៗពួកគេបានយកទៅបោះចោលអស់ ដូច្នេះតំណាងអយ្យការនៅតែរក្សាការចោទប្រកាន់ទុក នៅដដែល ដោយជនជាប់ចោទឈ្មោះ , ឈ្មោះ ហៅ និងឈ្មោះ

ពីបទ លួចមានស្ថានទម្ងន់ទោស សមគំនិតក្នុងអំពើលួច ដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីប្តោលទេសចណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩និងមាត្រា ៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ ត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីប្តោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BE០ ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

-មេធាវីការពារឲ្យជនជាប់ចោទឈ្មោះ ឈ្មោះ ហៅ និងឈ្មោះ បានធ្វើសេចក្តីសន្និដ្ឋានការពារសិទ្ធិថា : កូនក្តីរបស់ខ្ញុំបានឆ្លើយសារភាពនៅគ្រប់ដំណាក់កាលថាខ្លួនពិតជាបានលួចគាស់ទ្វារក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែនដូច្នេះសុំឲ្យលោកប្រធានក្រុមប្រឹក្សា មេត្តាជួយសម្រាលទោសឲ្យកូនក្តីខ្ញុំដោយអនុគ្រោះចំណែកខ្ញុំឈ្មោះ ខ្លួនមិនបានដឹងអីទេសូមឲ្យលោកប្រធានក្រុមហ៊ុន មេត្តាលើកលែងឲ្យកូនក្តីខ្ញុំរួចខ្លួនពីបទចោទ ។

*-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ*

*-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ*

*-ក្រោយពីបានពិនិត្យភស្តុតាង និងឯកសារនានាក្នុងសំណុំរឿង*

*-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ*

*-ក្រោយពីក្រុមប្រឹក្សាបានពិនិត្យពិចារណាត្រឹមត្រូវតាមច្បាប់ហើយ*

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>យល់ឃើញថា</u>**

១/តាមរបាយការណ៍សំយោគលេខ២០៩ រ.ប.ក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៥ របស់អធិការដ្ឋាននគរបាលខណ្ឌចំការមន នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ផ្អែកតាមរបាយការណ៍នគរបាលប៉ុស្តិ៍ តាមពាក្យបណ្តឹងរបស់ជនរងគ្រោះ និងតាមចម្លើយសារភាពរបស់ជនជាប់ចោទឃើញថាឈ្មោះ និងឈ្មោះ ពិតជាបានប្រព្រឹត្តអំពើលួចមានស្ថានទម្ងន់ទោស (គាស់សោទ្វារក្រុមហ៊ុនលួចទូដែក ) កាលពីវេលាម៉ោង៣,១៥នាទី រំលងអាធ្រាតឈានចូលថ្ងៃ ទី៩ ខែតុលា ឆ្នាំ២០១៥ នៅចំណុចក្រុមហ៊ុនទេសចរណ៍ និងពាណិជ្ជដែលមានទីតាំងស្ថិតនៅផ្ទះលេខ៤១BE០ ផ្លូវ៣៤៨ ក្រុម១៨ ភូមិ៤ សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រាកដមែនចំណែកជនជាប់ចោទឈ្មោះ ពិតជាបានសមគំនិត ផ្តល់មធ្យោបាយធ្វើសកម្មភាព និងទទួលផលចោលរកម្មក្នុងករណីនេះប្រាកដមែនរីឯជនជាប់ឈ្មោះ ដែលជាប្រពន្ធរបស់ជនជាប់ចោទឈ្មោះ ក៏ជាអ្នកទទួលផលចោរកម្មក្នុងករណីខាងលើនេះដែរ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថា: កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៣,១៥នាទីខ្លួនពិតជាបានធ្វើសកម្មភាពគាស់ទ្វារក្រុមហ៊ុននៅម្តុំទួលស្វាយព្រៃដោយលួចបានទូរដែកប្រាកដមែន ។ មុនដំបូងឈ្មោះ បានយកម៉ូតូមួយ គ្រឿងម៉ាកសេ១០០ក្បូរ៉ង្វើលពណ៌ក្រហមគ្មានស្លាកលេខពីឈ្មោះ ( ) មកតាក់ឌុបរ៉ឺម៉កខ្លួនបានដឹកបក្ខពួកផ្សេងទៀតឈ្មោះ , , និង ដើររកគាស់ផ្ទះរបស់គេយកទ្រព្យសម្បត្តិ ។ ពេលខ្លួនធ្វើដំណើរមកដល់ទួលស្វាយព្រៃក៏បានឃើញក្រុមហ៊ុនរបស់គេចាក់សោនៅខាងក្រៅ ពេលនោះពួកខ្លួនក៏បានឈប់ម៉ូតូ ហើយក៏បានយកខ្ទុឡីវីសមកឆ្កឹះសោសូឡិចទ្វារខាងមុខ ចំណែកឈ្មោះ ឆ្កឹះសោទ្វារខាងក្នុងរួចបាននាំគ្នាចូលទៅក្នុង ក្រុមហ៊ុនរើកកាយនិងលួចយកបានទូរដែក១នៅជាន់ខាងលើហើយក៏នាំគ្នាដឹកតាមរ៉ឺម៉កទៅ ផ្ទះរបស់ឈ្មោះ ដើម្បីគាស់បានឃើញលុយជាច្រើន និងឯកសាផ្សេងទៀត រួចហើយបានចែកលុយគ្នាខ្លួនទទួលបានប្រាំពាន់ដុល្លាអាមេរិក រីឯឯកសារទាំងនោះត្រូវបានដុតចោល បន្ទាប់មកខ្លួនយកលុយចំនួន៤ពាន់

ដុល្លារអាមេរិក ទៅផ្ញើនឹងឈ្មោះ នៅសល់ប៉ុន្មានខ្លួនបានយកទៅចាយវាយ និងចែកអ្នកជិតខាងនៅស្វាយរៀង លុះដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោងប្រហែល ១៣,០០នាទីរសៀលពេលដែលខ្លួនកំពង់អង្គុយលេង ជាមួយឈ្មោះ និងឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមក ឃាត់ខ្លួនតែម្តង ចំណែកឈ្មោះ បានរត់គេចខ្លួនបាត់ ។

៣/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថាៈ កាលពីថ្ងៃទី ០៩ ខែ តុលា ឆ្នាំ២០១៥ ខ្លួនពិតជាបានយកម៉ូតូទៅឈ្មោះ ជិះធ្វើសកម្មភាពគាស់ផ្ទះ របស់គេលួចទូរដែកប្រាក់ដមែន ។ មុនដំបូងនៅល្ងាចថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ឈ្មោះ បានឲ្យទូរសព្ទមកខ្លួនឲ្យយកទៅគេនៅម្តុំផ្សាអំពៅ ពេលនោះក៏បានជិះម៉ូតូម៉ាក សងសេ១០០ ករ៉េផ្លើសពណ៌ក្រមគ្មានស្លាកលេខ ហើយឈ្មោះ ក៏បានឌុបម៉ូតូខ្លួនជិះរួច ខ្លួនក៏បានជិះម៉ូតូរបស់ឈ្មោះ ត្រលប់មកផ្ទះវិញ មូលហេតុដែលឈ្មោះ ឌុបម៉ូតូរ គឺម៉ូតូរបស់ខ្លួនមានប្រដាប់សន្តោងរ៉ឺម៉កស្រាប់ ។ លុះព្រឹកថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ វេលាម៉ោងប្រហែល៧,០០នាទីឈ្មោះ បានទូរសព្ទប្រាប់ខ្លួនថាឲ្យមកយកម៉ូតូ និង បានឲ្យលុយខ្លួនចំនួន១លានរៀល ។ រហូតដល់ថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៥ ម៉ោង ប្រហែល១៣,០០នាទី ខ្លួនក៏បានជិះម៉ូតូមកអង្គុយ លេងជាមួយឈ្មោះ និងឈ្មោះ នៅផ្ទះរបស់ឈ្មោះ ស្រាប់តែមានសមត្ថកិច្ចមកឃាត់ខ្លួនជាមួយឈ្មោះ នាំមកតែ ម្តង ចំណែកឈ្មោះ បាន រត់គេចខ្លួនបាត់ ។

៤/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ឆ្លើយថាៈ ខ្លួនពិតជាបានចូលរួម គាស់ផ្ទះគេពិតមែន និងមានគ្នាទាំងអស់៥នាក់ក្នុងនេះមានឈ្មោះ ឈ្មោះ , ឈ្មោះ ...,ឈ្មោះ .. ហៅ .. ។ ពេលនោះពួកខ្លួនលួចបានទូដែក១ យកទៅបើកនៅ ផ្ទះខ្លួន ក្នុងនោះមានលុយចំនួន៥០,០០០$ រួចហើយក៏បានចែកគ្នា ដោយខ្លួនបានចំនួន ១០,០០០$ លុះ សល់ពីនោះទុកឲ្យបក្សពួក៤នាក់ទៀតចែកគ្នា ចំណែកទូរដែកនេះបាន បោះចោល ជាមួយឯកសារនៅក្បែរវត្តផ្សារអំពៅ ។

៥/តាមចម្លើយបណ្តឹងរដ្ឋប្បវេណីឈ្មោះ ឆ្លើយថាៈ កាលពី ថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៥ខ្លួនបានចេញពីក្រុមហ៊ុនដែលមានទីតាំងផ្ទះលេខ៤១BEo ផ្លូវលេខ ៣៤៨ ក្រុមទី១៨ ភូមិ៤ សង្កាត់ស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ ត្រលប់ទៅ សម្រាក់នៅផ្ទះលុះដល់ម៉ោងប្រហែល៤,០០នាទីទាបភ្លឺ ចូលថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ ពេលខ្លួនកំពង់សម្រាកក៏មានសមត្ថកិច្ចបានទូរសព្ទប្រាប់ថា ក្រុមហ៊ុនរបស់ខ្លួនត្រូវមាន ចោរលួចគាស់ទ្វា ពេលនោះខ្លួនក៏បានមកមើល ទើបដឹងថាបាត់ទូរដែកចំនួន១ ហើយ ក្នុងទូរដែកនេះ មានប្រាក់ចំនួន៥០,០០០$ , ប្រាក់រៀលចំនួន២លានរៀល , ឯកសារប្លង់ ដីមួយចំនួន , សៀវភៅធនាគារចំនួន៣ក្បាល និងបាត់ម៉ាស៊ីនស្កេនចំនួន១ផងដែរ ។

៦/តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ ,ឈ្មោះ , ឈ្មោះ បានឆ្លើយស៊ីសង្វាក់ទៅនឹងចម្លើយរបស់បណ្តឹងរដ្ឋប្បវេណី , ចម្លើយសាក្សីនិង ភស្តុ តាងនានានៅក្នុងសំណុំរឿងថាជនជាប់ចោទពិតជាបានប្រព្រឹត្តអំពើលួចគាស់ទ្វា ក្រុមហ៊ុនស៊ី ហ្គោលទេសចរណ៍ និងពាណិជ្ជ ពិតប្រាកដមែន ។

៧/ជនជាប់ចោទមានស្មារតីល្អនៅពេលប្រព្រឹត្តបទល្មើស អំពើប្រព្រឹត្តរបស់ជន ជាប់ជាប់ចោទឈ្មោះ , ឈ្មោះ "..' ពី , ឈ្មោះ . . .... . , និងឈ្មោះ. . បានធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសណ្តាប់ធ្នាប់សង្គមយ៉ាង

ធ្ងន់ធ្ងរដែលដែលធ្វើឲ្យបាត់បង់ទ្រព្យសម្បត្តិរបស់ជនរងគ្រោះ និងផ្ទុយទៅនឹងច្បាប់កំណត់ ។

៨/ជនជាប់ចោទឈ្មោះ និងជនជាប់ចោទឈ្មោះ ជា<u>អនីតិជន</u>តុលាការគប្បីពិចារណាពីស្ថានសម្រាល ។

៩/តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។

១០/មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ ភេទប្រុស <u>អាយុ១៤</u>ឆ្នាំ ជនជាតិខ្មែរ , ឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ , ឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ត្រូវជាប់ចោទពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរត្រូវជាប់ចោទពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញាតិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

១១/វត្ថុចាប់យកមាន:

១១.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ១ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែត្បា និង អង្គចងចាំចំនួន១ គប្បីប្រគល់ឲ្យម្ចាស់ដើមវិញ ។

១១.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដាក់គ្រឿងញៀនចំនួន១តុលាការគប្បីសម្រេចរឹបអូស ។

១២/ដើមបណ្តឹងសុំទាមទារសំណង ជាប្រាក់ដែលបានបាត់បង់ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក) ,លុយខ្មែរចំនួន២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈដែល បានបាត់បង់ជាឯកសារ តុលាការគប្បីសម្រេចតាមច្បាប់ ។

<u>**ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ**</u>

**វិនិច្ឆ័យសេចក្តី**

១/ផ្តន្ទាទោស:

១.១/ឈ្មោះ ភេទប្រុស <u>អាយុ១៤ឆ្នាំ</u> ជនជាតិខ្មែរដាក់ពន្ធនាគារកំណត់រយៈ០២ឆ្នាំ (ពីរឆ្នាំ) និងឈ្មោះ ហៅ ភេទប្រុស អាយុ២៧ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាគារក្នុងម្នាក់កំណត់រយៈពេល០៤ឆ្នាំ (បួនឆ្នាំ) ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុច ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១សង្កាត់ ទួលស្វាយព្រៃ

១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.២/ផ្តន្ទាទោសលើឈ្មោះ ហៅ ភេទប្រុស អាយុ១៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល០២ឆ្នាំ (ពីរឆ្នាំ) ពីបទ សមគំនិតក្នុងអំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រ ព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា២៩,៣៥៣, ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

១.៣/ផ្តន្ទាទោសលើឈ្មោះ ភេទស្រី អាយុ២២ឆ្នាំ ជាតិខ្មែរដាក់ពន្ធនាងគារកំណត់រយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទ ទទួលផលចោរកម្ម ក្រុមហ៊ុនស៊ីហ្គោលទេសចរណ៍ និងពាណិជ្ជ ដែលមានទីតាំងនៅផ្ទះលេខ៤១BEo ផ្លូវលេខ៣៤៨ ក្រុម១៤ ភូមិ១៤ សង្កាត់ទួលស្វាយព្រៃ១ ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី៩ ខែតុលា ឆ្នាំ២០១៥ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា៣៩៩,៤០០ នៃក្រមព្រហ្មទណ្ឌ ។

២/វត្ថុចាប់យកមានៈ

២.១/ម៉ូតូមួយគ្រឿងម៉ាក CITY Pluo ពណ៌ក្រហមគ្មានស្លាកលេខ១ម៉ាស៊ីន ០១៧៤៤៦ (ម៉ូតូចាស់មានកែញ្ចក់ និង អង្គចងចាំចំនួន១ ប្រគល់ឲ្យម្ចាស់ដើមវិញ ។

២.២/ញញួរចំនួន២ , ដែកដាប់ចំនួន៣ , ដែកគាស់ចំនួន១ , កន្ត្រៃចំនួន១ , កូនកាំបិតចំនួន២ , កាំបិតតាំងតោចំនួន៤ , ដាវចំនួន១ និងដបសម្រាប់ដាក់គ្រឿងញៀនចំនួន១រឹបអូស ។

៣/បង្គាប់ឲ្យឈ្មោះ , ឈ្មោះ ,ឈ្មោះ និងឈ្មោះ រួមគ្នាសងសំណងដែលបានបាត់បង់ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៥០,០០០$ (ប្រាំម៉ឺនដុល្លាអាមេរិក) , លុយខ្មែរចំនួន ២,០០០,០០០រៀល (ពីរលានរៀល) និងសម្ភារៈ ដែល បានបាត់បង់ជាឯកសារ ទាមទារលើសពីនេះបដិសេធន៍ចោល ។

៤/បង្គាប់ឲ្យចេញដីកាចាប់នឹងឃុំខ្លួនឈ្មោះ ដើម្បីអនុវត្តទោសតាមអំណាចសាលក្រមតាមមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

-សាលក្រមនេះជំនុំជំរះនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១៦ និងប្រកាសជាសាធារណៈនៅថ្ងៃទី២២ខែមេសា ឆ្នាំ ២០១៦ចំពោះមុខជនជាប់ចោទឈ្មោះ , ឈ្មោះ និងឈ្មោះ កំបាំងមុខជនជាប់ចោទឈ្មោះ និងដើមបណ្តឹងរដ្ឋប្បវេណីទុកសិទ្ធិប្តឹងទាស់ និងបើផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

-បានចម្លងត្រឹមត្រូវតាមច្បាប់ដើម-
រាជធានីភ្នំពេញ ថ្ងៃទី២២ខែមេសា ឆ្នាំ២០១៦
ក្រឡាបញ្ជី